សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លោក ហាម មុំហេង**
**កញ្ញា យ៉ិន លក្ខិណា**

សាស្ត្រាចារ្យណែនាំ
លោក **គង់ ស៊ីផាន់ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ លេខកូដថ្នាក់ L4C4 និងL4C5 នៃសកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលជាដៃគូរសរសេរសារណាជាមួយគ្នា សូមធ្វើការដឹកគុណ និងថ្លែងអំណរគុណចំពោះ ៖

អ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់យើងខ្ញុំ ព្រមទាំងផ្តល់នូវគុណូបក្ការៈដ៏ធំធេង ដោយបានបីបាច់ថែរក្សា ថ្នាក់ថ្នម ផ្តល់ការអប់រំ ប្រៀនប្រដៅ និងជួយទំនុកបំរុងគ្រប់យ៉ាង មិនថាកម្លាំងកាយ កម្លាំងចិត្ត ស្មារតី ថវិកា និងសំភារៈផ្សេងៗ ដើម្បីជំរុញឱ្យយើងខ្ញុំមានការប្រឹងប្រែងរៀនសូត្រក្នុងទិសដៅដើម្បីក្លាយទៅជាបុគ្គលមួយរូប ដែលសង្គមខ្មែរទាំងមូលទទួលស្គាល់ និងមានតម្លៃសម្រាប់សង្គមជាតិ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាពិសេសសូមដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក-លោកស្រីបណ្ឌិត និងលោក-លោកស្រីសាស្រ្តាចារ្យបំរើការក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានខិតខំបង្រៀនយើងខ្ញុំរហូតដល់ការបញ្ចប់។

ជាបន្តទៅនេះ យើងខ្ញុំក៏សូមថ្លែងអំណរអរគុណយ៉ាងក្រៃលែងចំពោះលោកសាស្រ្តចារ្យ **កង ស៊ីផាន់ណារ៉ា** និងអ្នកស្រីសាស្រ្តាចារ្យ **ម៉ូយ ធីតា** ជាព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្ហាញ ណែនាំ និងបានផ្តល់ចំណេះដឹង ព្រមទាំងអនុសាសន៍ដែលទាក់ទង និងសារណារបស់យើងខ្ញុំឱ្យកាន់តែមានភាពប្រសើរឡើង។ លើសពីនេះលោកសាស្រ្តាចារ្យទាំងពីរបានចំណាយពេលដ៏មានតម្លៃដើម្បីកែតម្រូវរាល់កំហុសឆ្គងដែលកើតមានក្នុងសារណានេះ រហូតដល់សារណារបស់យើងខ្ញុំបានទទួលជោគជ័យ។

ជាអវសានេះ យើងខ្ញុំទាំងពីរពុំមានពាក្យអ្វីក្រៅពីពាក្យថា អរគុណយ៉ាងជ្រាលជ្រៅបំផុត និងមានតែលើកម្រាមដៃដប់ បួងសួងដល់សកទេវរាជ ស្តេចទេវតារក្សាទ្វីបលោកឱ្យតាមជួយថែរក្សាដល់លោកអ្នកមានគុណទាំងពីរ ព្រមទាំងលោក-លោកស្រីសាស្រ្តចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់អោយជួបប្រទះនឹងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈកុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១០កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥

ត្រូវនឹង ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៩

**ហាម មុំហេង យ៉ិន លក្ខិណា**

# អារម្ភកថា

បន្ទាប់ពីសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល៤ឆ្នាំ សាកលវិទ្យាល័យបានតម្រូវឱ្យ យើងខ្ញុំទាំងពីរជ្រើសរើសប្រធានបទធ្វើសារណា ដើម្បីវាស់ស្ទង់អំពីកម្រិតនៃចំណេះដឹងរបស់យើងខ្ញុំ ដែលបានខិតខំប្រឹងប្រែងសិក្សាក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។

ប្រធានបទនៃសារណារបស់យើងខ្ញុំទាំងពីរដែលបានជ្រើសរើសស្តីពី " **សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល** " មូលហេតុដែលយើងខ្ញុំទាំងពីរលើកយកប្រធានបទនេះមកសិក្សាស្រាវជ្រាវពី ព្រោះវាជាប្រធានបទមួយដែលថ្មីទាក់ទងនឹងសញ្ជាតិខ្មែររបស់រូបវន្តបុគ្គលនៅក្នុងបរិបទច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ម៉្យាងវិញទៀតការជ្រើសរើសយកប្រធានបទនេះ យើងខ្ញុំទាំងពីរមានគោលបំណង់ចង់ពង្រឹងសមត្ថភាពផ្នែកច្បាប់ ជាពិសេសក្នុងការទទួលសញ្ជាតិខ្មែរ ក៏ដូចជាទុកជាឯកសារឱ្យអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ បានយល់អោយកាន់តែស៊ីជម្រៅអំពីការទទួលសញ្ជាតិខ្មែរនៃច្បាប់ ស្តីពីសញ្ជាតិនេះ។ ជាងនេះទៅទៀត យើងខ្ញុំផ្ទាល់ក៏ចង់សិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីការទទួលសញ្ជាតិខ្មែរផង ថាមានលក្ខណៈយ៉ាងដូចម្តេច? និងមានចំនុចល្អយ៉ាងដូចម្តេចខ្លះ ជាពិសេសសំរាប់ជនបរទេសដែលជាអ្នកវិនិយោគ និងជនអន្តោប្រវេសន៍ស្របច្បាប់។

ដូច្នេះទម្រាំតែសារណានេះទទួលបានលទ្ធផលជាទីគាប់ប្រសើរបែបនេះយើងខ្ញុំទាំងពីរបានជួបនូវបញ្ហាជាច្រើនដូចជាកង្វះឯកសារទាក់ទងទៅនិងច្បាប់ ស្តីពីសញ្ជាតិខ្មែរនេះ និងការបកប្រែចេញពីភាសាបរទេសដែលជាបញ្ហាចំបង។ យ៉ាងណាមិញ ដោយមានការជ្រំជ្រែងពីសំណាក់សាស្ត្រាចារ្យណែនាំ និងមិត្តភក្តិដែលបានជួយផ្តល់នូវឯកសារមួយចំនួន និងការខិតខំប្រឹងប្រែងអស់ពីសមត្ថភាព យើងខ្ញុំបានធ្វើនូវសារណាមួយនេះ។

ជាចុងក្រោយនេះ យើងខ្ញុំរីករាយ និងរងចាំទទួលជានិច្ចនូវរាល់មតិរិះគន់ និងកែលម្អដើម្បីស្ថាបនាពីសំណាក់ឯកឧត្តម លោក លោកស្រី និស្សិត និងបងប្អូនជនរួមជាតិដែលនិយមសិក្សាស្រាវជ្រាវលើឯកសារដែលពាក់ព័ន្ធនឹងវិស័យច្បាប់។

ដោយក្តីគោរពរាប់អានដ៏ជ្រាលជ្រៅជាទីបំផុតពីយើងខ្ញុំទាំងពីរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**..........១
**ជំពូកទី ១ សញ្ញាណទូទៅនៃការទទួលបានសញ្ជាតិខ្មែរ**..........៤
**ផ្នែកទី ១ សាវតា**..........៤
កថាខណ្ឌទី ១ និយមន័យ..........៥
កថាខណ្ឌទី ២ ធាតុផ្សំនៃអត្តសញ្ញាណរបស់រូបវន្តបុគ្គល..........៨
**ផ្នែកទី ២ ការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល**..........១៣
កថាខណ្ឌទី ១ លិខិតបទដ្ឋានគតិយុត្ត..........១៣
កថាខណ្ឌទី ២ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល..........១៤
១ ការទទួលបានសញ្ជាតិខ្មែរពីកំណើត..........១៤
២ ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ..........១៧
៣ ការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍..........១៩
៤ ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម..........២២
**ជំពូកទី ២ ទម្រង់បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងច្បាប់សញ្ជាតិ**.......... ២៦
**ផ្នែកទី ១ ទម្រង់បទដ្ឋានគតិយុត្ត និងអានុភាពនៃការទទួលបានសញ្ជាតិខ្មែរ**..........២៦
កថាខណ្ឌទី ១ លិខិតបទដ្ឋានគតិយុត្តនៃការទទួលបានសញ្ជាតិខ្មែរ..........២៦
១ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរពីកំណើត..........២៦
២ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ..........២៨
៣ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍.៣០
៤ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម..........៣៣
កថាខណ្ឌទី២ អានុភាពនៃការទទួលបានសញ្ជាតិខ្មែរ..........៣៧
**ផ្នែកទី ២ ការបាត់បង់សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល និងទោសបញ្ញត្តិ**..........៤២
កថាខណ្ឌទី ១ ការបាត់បង់សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល..........៤២
កថាខណ្ឌទី ២ ទោសបញ្ញត្តិ..........៤៤
**សេចក្តីសន្និដ្ឋាន**..........៤៥
**អនុសាសន៍**..........៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅលើសាកលលោកមានប្រទេសជាច្រើនដែលស្ថិតនៅលើទ្វីបចំនួន ៧(ប្រាំពីរ) ក្នុងភពផែនដី ហើយទ្វីបទាំងនោះ មានដូចជា ទ្វីបអាស៊ី ទ្វីបអាហ្វ្រិក ទ្វីបអាមេរិកខាងជើង ទ្វីបអាមេរិកខាងត្បូង ទ្វីបអង់តាកទិក ទ្វីបអឺរ៉ុប និងទ្វីបអូសេអានី(ទ្វីបអូស្ត្រាលី)។[1] ដោយទ្វីបទាំង ៧ (ប្រាំពីរ) នោះមានការប្រមូលផ្តុំដោយរដ្ឋ និងប្រទេសជាច្រើន ដែលប្រកាន់នូវរបបនយោបាយខុសៗគ្នា និងប្រព័ន្ធច្បាប់ផ្សេងៗពីគ្នាផងដែរ។ រដ្ឋមួយដែលអាចមានលក្ខណៈជារដ្ឋមួយពេញលេញបាន លុះត្រាតែមានធាតុផ្សំ ៤ ( បួន ) យ៉ាងគឺ ទឹកដី ប្រជាជន របបនយោបាយ និងអធិបតេយ្យភាពនៃរដ្ឋ។ ទើបប្រទេសទាំងអស់នោះអាចក្លាយជារដ្ឋពេញលេញ និងអាចចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ដែលមានចំនួន ១៦៨ ( មួយរយហុកសិបប្រាំបី ) ប្រទេស។[2]

ជាពិសេសប្រជាពលរដ្ឋនៃរដ្ឋនីមួយៗ ត្រូវតែមានចំណងគតិយុត្តជាមួយនឹងរដ្ឋ តាមរយៈការផ្តល់សញ្ជាតិជូនប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេស និងក្រៅប្រទេស ដោយចងភ្ជាប់ដោយលិខិតបទដ្ឋានគតិយុត្តផងដែរ។ ដូចនេះ បានសបញ្ជាក់ឱ្យឃើញថា សញ្ជាតិពិតជាមានទំនាក់ទំនងយ៉ាងជិតស្និតរវាងរដ្ឋ និងប្រជាពលរដ្ឋ ដែលបង្ហាញពីអត្តសញ្ញាណជាតិរបស់រដ្ឋមួយពេញលេញ។ ក្នុងនោះដែរគ្រប់បណ្តារដ្ឋទាំងអស់ក៏ត្រូវតែមានរបបនយោបាយ និង លិខិតបទដ្ឋានគតិយុត្តនានា សម្រាប់គ្រប់គ្រងអនុវត្ត និងដឹកនាំប្រទេសទៅតាមបរិបទនៃសង្គម។ ក៏ដូចជាប្រទេសកម្ពុជាផងដែរ បានសម្រេចជ្រើសរើសយករបបនយោបាយលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលស្របទៅតាមមាត្រា ១ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[3] ដែលជាច្បាប់កំពូលសម្រាប់ជាគោលដៅដឹកនាំរបស់ប្រទេសកម្ពុជា។ លើសពីនេះទៅទៀត បណ្តារដ្ឋ ទាំងអស់ត្រូវតែមានប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងប្រទេស ដែលប្រព័ន្ធច្បាប់មានចំនួន ០២ ( ពីរ ) ធំ គឺប្រព័ន្ធច្បាប់និយាយ ( Common Law ) និងប្រព័ន្ធច្បាប់សរសេរ ( Civil Law )។ ចំណែកប្រព័ន្ធច្បាប់និយាយវិញ គឺត្រូវបានប្រទេសកាណាដា និងប្រទេសមួយចំនួនទៀត នៅទ្វីបអ៊ឺរ៉ុប ឬប្រទេសដែលកាន់នីតិអង់គ្លេស ( និយាយភាសាអង់គ្លេស ) និងបណ្តាប្រទេសដែលជាសមាជិកសមាគមន៍ Common Wealth បានជ្រើសរើសប្រព័ន្ធច្បាប់នេះសម្រាប់ការគ្រប់គ្រងប្រទេស ដោយការគ្រប់គ្រង ឬការវិនិច្ឆ័យនានាត្រូវតែគោរពទៅតាមព្រះរាជសាលាយុត្តិធម៌ជាអ្នកកំណត់។ ចំណែកឯរាល់ការដឹកនាំប្រទេសមួយចំនួនដូចជា ថៃ ឡាវ កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី -ល- និងប្រទេសកម្ពុជា បានជ្រើសរើសប្រព័ន្ធច្បាប់សរសេរ ( Civil Law ) ដោយត្រូវការជាចាំបាច់នូវច្បាប់សរសេរគឺរដ្ឋធម្មនុញ្ញ[4] ជាច្បាប់កំពូលសម្រាប់ដឹកនាំប្រទេស។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលក្នុងការដឹកនាំ

---

[1] យោងតាមគេហទំព័រ https://www.countries-ofthe-world.com

[2] យោងតាមគេហទំព័រ http://www.un.org of United Nations

[3] យោងតាមមាត្រា ១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[4] យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

គ្រប់គ្រង និងការអនុវត្តផ្តល់នូវសិទ្ធិ និងសេរីភាពទៅដល់ប្រជាពលរដ្ឋក្នុងប្រទេសនីមួយៗ តាមរយៈច្បាប់កំណត់ ដើម្បីឱ្យមានដំណើរការល្អក្នុងការគ្រប់គ្រងទៅតាមប្រព័ន្ធច្បាប់ ( Civil Law ) ឬការកំណត់នូវរាល់ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ស្របទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសជាដាច់ខាត។

បើមិនគោរពទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ទេ នាំឱ្យច្បាប់កំពូលនេះមានលក្ខណៈអធម្មនុញ្ញភាព ដោយសារការត្រួតពិនិត្យពីក្រុមប្រឹក្សាធម្មនុញ្ញភាពនេះ។ លើសពីនេះគ្រប់បណ្តាប្រទេសទាំងអស់ត្រូវតែបង្កើតច្បាប់ដែលទាក់ទងទៅនឹងសញ្ជាតិរបស់ពលរដ្ឋខ្លួន ដើម្បីចងនូវចំណងគតិយុត្តរវាងពលរដ្ឋទៅនឹងរដ្ឋអធិបតេយ្យភាព[5] តាមរយៈអត្រានុកូលដ្ឋាន ដោយគោរពទៅតាមជំពូកទី ៣ ស្តីពី សិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចាប់ពី មាត្រា៣១ ដល់មាត្រា៥០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ដូចនេះ រាល់ការបង្កើតបទដ្ឋានគតិយុត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែគោរព និងស្របទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣[6]ដាច់ខាត។ ប៉ុន្តែរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏ត្រូវបានបង្កើតឡើងចំនួន ៦ ( ប្រាំមួយ ) ដង តាំងពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣[7]។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើវិសោធនកម្មចំនួន ៨ ( ប្រាំបី ) លើកដើម្បីឱ្យរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រឹតតែមានលក្ខណៈកាន់តែប្រសើរឡើងទៅតាមបរិបទនៃសង្គមខ្មែរនាពេលបច្ចុប្បន្ន[8]។ ក្រោយពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣បានបង្កើតមកច្បាប់ស្តីពីសញ្ជាតិក៏ត្រូវបានបង្កើតឡើងចំនួន ០២ ( ពីរ ) លើកក្នុងឆ្នាំ១៩៩៦ និងឆ្នាំ២០១៨នេះដើម្បីឱ្យស្របទៅតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។

ជាពិសេស បទដ្ឋានគតិយុត្តដែលទាក់ទងទៅនឹងច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ ដែលរួមមានច្បាប់ ស្តីពី សញ្ជាតិឆ្នាំ២០១៨ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗជាអាទិ៍។ រាល់លិខិតបទដ្ឋានគតិយុត្តទាំងនេះ បានបង្ហាញពីកាតព្វកិច្ច លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចូលសញ្ជាតិខ្មែរ ដែលរូបវន្តបុគ្គលមានសិទ្ធិទទួលបាន ឬពីការទាមទារសញ្ជាតិ ឬការផ្តល់សញ្ជាតិពីរដ្ឋ ដោយមិនគិតពីពណ៌ សម្បុរ រូបរាងកាយ ភេទ ភាសា និងជនជាតិផ្សេងៗទៀតឡើយ។ ប្រសិនបើ រូបវន្តបុគ្គលនោះ គោរពទៅតាមលក្ខខណ្ឌនៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ បានកំណត់ចំពោះរូបវន្តបុគ្គលដូចជា ៖ ការទទួលបានសញ្ជាតិខ្មែរពីកំណើត ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ ការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ និងការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ជាពិសេសក៏បានកំណត់ពីការបាត់សញ្ជាតិខ្មែរផងដែរ។ ដោយយោងតាម

[5] យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០

[6] យោងតាមជំពូកទី៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[7] យោងតាមអារម្ភកថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[8] យោងតាមអារម្ភកថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ នៃច្បាប់ ស្តីពីសញ្ជាតិឆ្នាំ២០១៨។[9] ទើបរូបវន្តបុគ្គលនោះ អាចចូលសញ្ជាតិខ្មែរដោយស្របទៅតាមច្បាប់ ស្តីពី សញ្ជាតិ បានកំណត់ ហើយចំពោះនីតិវិធីនៃការចូលសញ្ជាតិវិញ ត្រូវគោរពទៅតាមអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨[10]។

ដូចនេះ គ្រប់រូបវន្តបុគ្គលទាំងអស់ដែលទទួលបានសញ្ជាតិខ្មែរ គឺត្រូវតែមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ច ដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់រូបវន្តបុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ដោយច្បាប់។[11] រាល់បទដ្ឋានគតិយុត្តផ្សេងៗ ដែលទាក់ទងនឹងសញ្ជាតិខ្មែរ ត្រូវអនុវត្ត និងអ្នកប្រតិបត្តិចំពោះច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា គឺអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃដែលជាអ្នកមានសមត្ថកិច្ចដឹកនាំអនុវត្ត ដោយយោងតាមមាត្រា ៥ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨។[12] ហេតុដូចនេះ រាល់លិខិតបទដ្ឋានគតិយុត្តនានា លក្ខខណ្ឌនៃការចូលសញ្ជាតិខ្មែរ អានុភាព បែបបទ និងនីតិវិធី និងសិទ្ធិសេរីភាពរបស់ពលរដ្ឋខ្មែរ ត្រូវបានកំណត់នៅក្នុងជំពូកខាងក្រោមនៃប្រធានបទ។

ដូចនេះ ខ្លឹមសារនៃសារណាខាងក្រោមនឹងបង្ហាញអំពី ៖ ជំពូកទី១ សញ្ញាណទូទៅនៃការទទួលបានសញ្ជាតិខ្មែរ និងជំពូកទី២ ទម្រង់ទម្រង់បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងច្បាប់សញ្ជាតិដែលបានបង្ហាញដូចខាងក្រោម។

[9] យោងតាមមាត្រា ២ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[10] យោងតាមអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[11] យោងតាមមាត្រា ៣១ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[12] យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

## ជំពូកទី ១ សញ្ញាណទូទៅនៃការទទួលបានសញ្ជាតិខ្មែរ

ជំពូកទី១ សញ្ញាណទូទៅនៃការទទួលបានសញ្ជាតិខ្មែរនេះ ត្រូវបានបង្កប់ទៅដោយលក្ខណៈទូទៅនៃសញ្ជាតិ ដែលបង្ហាញអំពី ផ្នែកទី១ សារតា ( កថាខណ្ឌទី ១ និយមន័យ និងកថាខណ្ឌទី ២ ធាតុផ្សំនៃអត្តសញ្ញាណរបស់រូបវន្តបុគ្គល ) និងផ្នែកទី២ ក៏បានបង្ហាញអំពី ការទទួលបានសញ្ជាតិខ្មែរ ( កថាខណ្ឌទី ១ លិខិតបទដ្ឋានគតិយុត្ត និងកថាខណ្ឌទី ២ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល ) ដែលមានបង្ហាញដូចខាងក្រោមនេះ។

### ផ្នែកទី ១ សារតា

សញ្ជាតិខ្មែរ គឺត្រូវបានច្បាប់កំណត់ និងទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្នុងជំពូកទី៣ ស្តីពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ[13] ដែលទទួលបានតាមរយៈសញ្ជាតិដែលរដ្ឋបានកំណត់ក្នុងច្បាប់។ ចំពោះការទទួលបានសញ្ជាតិខ្មែរ គឺត្រូវគោរពទៅតាមលក្ខខណ្ឌណាមួយដែលកំណត់នៅក្នុងច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨[14] ដោយច្បាប់ស្តីពីសញ្ជាតិ ចាស់ឆ្នាំ១៩៩៦ ត្រូវបានទុកជានិរាករណ៍ និងជំនួសដោយច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨នេះ។ លើសពីនេះសញ្ជាតិខ្មែរ គឺបានបង្ហាញអំពីអត្តសញ្ញាណជាតិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយមានសិទ្ធិ សេរីភាព និងករណីយកិច្ចក្នុងការអនុវត្តពេញលេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គ្រប់រូបវន្តបុគ្គលទាំងឡាយណា ដែលទទួលបានពីការផ្តល់ និងការទាមទារសញ្ជាតិខ្មែរពីរដ្ឋខ្មែរ គឺជាប្រជាពលរដ្ឋខ្មែរ[15]។ ចំពោះការទទួល ឬការផ្តល់សញ្ជាតិពីរដ្ឋ គឺត្រូវតែគោរពទៅតាមបែបបទ និងនីតិវិធីនៃការចូលសញ្ជាតិខ្មែរដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ( ចំពោះជនបរទេស ) និងចំពោះប្រជាពលរដ្ឋខ្មែរវិញ គឺត្រូវបានរដ្ឋខ្មែរផ្តល់សញ្ជាតិឱ្យតាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋានស្របច្បាប់តាមឃុំ/សង្កាត់នៃទីកន្លែងកំណើតរបស់រូបវន្តបុគ្គលម្នាក់ៗ។ អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ចយោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ ២០០០។[16]

ដូចនេះ មុននឹងឈានទៅដល់ការបកស្រាយទៅលើខ្លឹមសារនៃប្រធានបទ យើងគួរគប្បីយល់ច្បាស់ពីនិយមន័យជាមុនសិន។

[13] យោងតាមជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[14] យោងតាមមាត្រា ២ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[15] យោងតាមមាត្រា ២ នៃច្បាប់ស្តីពីសញ្ជាតិចាស់ ឆ្នាំ១៩៩៦

[16] យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

**កថាខណ្ឌទី ១ និយមន័យ**

បើយោងតាមលិខិតបទដ្ឋានគតិយុត្ត “ **សញ្ជាតិ** ” គឺជាទំនាក់ទំនងតាមផ្លូវច្បាប់ ដែលកើតមានឡើងរវាងបុគ្គលនឹងរដ្ឋ។

បើយោងតាមអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០ បានឱ្យនិយមន័យ “ **សញ្ជាតិ** ” គឺជាចំណងរួមដែលចងភ្ជាប់ប្រជាពលរដ្ឋទៅនឹងរដ្ឋ តាមរយៈអត្រានុកូលដ្ឋាន។[17]

បើយោងតាមវចនានុក្រមច្បាប់ បោះពុម្ពលើកទី៤ ឆ្នាំ២០១៤ និពន្ធដោយលោក**ហ៊ីង ធីឫទ្ធិ** ដែលបានកំណត់ថា “ **សញ្ជាតិ** ” គឺជាចំណងខាងសាសនា និងនយោបាយដែលចងរូបវន្តបុគ្គល ឬនីតិបុគ្គលឱ្យជាប់ទៅនឹងរដ្ឋ។[18]

បើយោងតាមវចនានុក្រមរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ពាក្យថា “ **សញ្ជាតិ** ” មាននិយមន័យថា គឺជាការកើតឯង ការដុះឯង កន្លែងដែលកើត ឬស្រុកកំណើត។[19]

បើយោងតាមក្រុមប្រឹក្សាជាតិភាសាខ្មែរ បានកំណត់និយមន័យពាក្យថា " **សញ្ជាតិ** " នៅក្នុងសន្ទានុក្រមវិទ្យាសាស្ត្រនយោបាយ និងការទូត មានន័យថាជាចរិត ឬលក្ខណៈរបស់ប្រជាជាតិមួយដែលរស់នៅរួមគ្នាក្នុងក្របខណ្ឌនៃសហគមន៍មួយ ដែលមានទឹកដី ភាសា ទំនៀមទម្លាប់ និងសេចក្តីប៉ងប្រាថ្នារួម។ លក្ខណៈពិសេសនៃសញ្ជាតិរបស់ប្រជាជាតិមួយអាច កើតមានឡើងតាមរយៈកំណើត ឬធម្មជាតិនីយកម្ម សញ្ជាតូបនីយកម្ម អត្តសញ្ញាណកម្ម អាពាហ៍ពិពាហ៍ ការសុំកូនមកចិញ្ចឹមនីតិនីយកម្ម និងការផ្ទេរការគ្រប់គ្រងដែនដីពីរដ្ឋមួយទៅរដ្ឋមួយទៀតដោយយោងតាមគេហទំព័រ https://thmeythmey.com។[20]

ជាពិសេស “ **សញ្ជាតិ** ” គឺជាសញ្ជាតិផ្តាច់មុខរបស់រដ្ឋអធិបតេយ្យណាមួយដែលរដ្ឋនោះមានបុព្វសិទ្ធិ ឬឆន្ទានុសិទ្ធិសម្រេចក្នុងការផ្តល់ ឬការចាត់ចែង ឬប្រគល់សញ្ជាតិណាមួយទៅឱ្យរូបវន្តបុគ្គលស្របទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីសញ្ជាតិរបស់ប្រទេសនីមួយៗ ដែលបានកំណត់អំពីខ្លឹមសារក៏ដូចជា ច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្នុងនោះ ច្បាប់ ស្តីពី សញ្ជាតិបានកំណត់អំពីខ្លឹមសារនៃការទទួលសញ្ជាតិខ្មែរចំពោះរូបវន្តបុគ្គល ដោយបញ្ជាក់អំពីសិទ្ធិនៃទទួលបាន និងសិទ្ធិបោះបង់សញ្ជាតិខ្មែរចំពោះជនណាដែលមានបំណងដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំឡើយ ឬចំពោះរូបវន្តបុគ្គលណាដែលបានរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាយូរមកហើយ ឬជនបរទេសដែលបានបំពេញទៅតាមលក្ខខណ្ឌ ដោយយោងតាមមាត្រា ១ នៃច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨[21]។

---

[17]យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[18]យោងតាមវចនានុក្រមច្បាប់ បោះពុម្ពលើកទី៤ ឆ្នាំ២០១៤ និពន្ធដោយលោក **ហ៊ីង ធីឫទ្ធី**

[19] យោងតាមវចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត**

[20] យោងតាមគេហទំព័រ http://thmeythmey.com

[21] យោងតាមមាត្រា១ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

សរុបសេចក្ដីមក“ **សញ្ជាតិ** ”គឺជាពាក្យ ឬវាក្យស័ព្ទសម្រាប់ប្រើសម្គាល់ទៅលើរូបវន្តបុគ្គលរបស់ប្រទេសនីមួយៗ ដែលបានកើតនៅទីកន្លែងកំណើត ឬមានដើមកំណើតមកពីប្រទេសណាមួយ ដែលមានលក្ខណៈសម្គាល់ដោយអត្តសញ្ញាណជាតិនៃរដ្ឋ ដោយពុំមានការភាន់ច្រឡំគ្នានៃរដ្ឋឡើយ។ ម៉្យាងវិញទៀត “**សញ្ជាតិ** ” ក៏ត្រូវបានចងភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋទៅនឹងរដ្ឋ តាមរយៈសិទ្ធិ និងកាតព្វកិច្ច ដែលរដ្ឋបានកំណត់នៅក្នុងច្បាប់ជាធរមាន។ **ឧទាហរណ៍៖** ពលរដ្ឋខ្មែរត្រូវតែមានសញ្ជាតិខ្មែរ ឬពលរដ្ឋកូរ៉េខាងត្បូងត្រូវតែមានសញ្ជាតិ កូរ៉េខាងត្បូង ដែលស្ថិតទៅតាមច្បាប់ ស្ដីពី សញ្ជាតិរបស់ប្រទេសខ្មែរ និងកូរ៉េខាងត្បូងជាអ្នកកំណត់។

ចំពោះពាក្យថា“ **សញ្ជាតិខ្មែរ** ” វិញ គឺជាចំណងគតិយុត្ត និងនយោបាយដែលចងភ្ជាប់រូបវន្តបុគ្គលណាម្នាក់ ទៅនឹងព្រះរាជាណាចក្រកម្ពុជា ដោយយោងទៅតាមមាត្រា ៤ នៃច្បាប់ស្ដីពីសញ្ជាតិឆ្នាំ២០១៨។[22]

តាមក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧ មាត្រា ២១ ក៏បានកំណត់អំពីអត្ថន័យនៃពាក្យថា “**សញ្ជាតិខ្មែរ** ” គឺជាចំណងមួយខាងសាសនាផង និងខាងនយោបាយផង ដែលចងភ្ជាប់រូបវន្តបុគ្គល ឬនីតិបុគ្គលឱ្យជាប់ទៅនឹងរដ្ឋខ្មែរ។[23]

ពាក្យថា “ **សញ្ជាតិខ្មែរ** ” នេះគឺជាការចងភ្ជាប់ទំនាក់ទំនងគតិយុត្តរវាងប្រជាពលរដ្ឋខ្មែរទៅនឹងរដ្ឋ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់ ឬផ្ដល់ ឬការទាមទារសញ្ជាតិខ្មែរ ពីរូបវន្តបុគ្គលដែលរស់នៅក្នុងប្រទេសក្ដី ឬក្រៅប្រទេសក្ដី ឬជាជនបរទេសអន្តោប្រវេសន៍ក្ដី ឬវិនិយោគិនដែលបានធ្វើសម្បុរសធម៌ណាមួយទៅដល់រដ្ឋក្ដី ឬការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេសជាមួយប្រជាពលរដ្ឋខ្មែរក្ដី ឬការសុំកូនពេញលេញពីអន្តរប្រទេសមកកាន់ប្រទេសខ្មែរក្ដី។[24] រូបវន្តបុគ្គលទាំងនោះ គឺត្រូវបានការពារដោយរដ្ឋខ្មែរចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូប។ ដោយរាជរដ្ឋាភិបាលកម្ពុជា គឺត្រូវតែប្រគល់សិទ្ធិ និងកាតព្វកិច្ចចំពោះរូបវន្តបុគ្គលទាំងនោះដូចគ្នាទៅនឹងប្រជាពលរដ្ឋខ្មែរដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានកំណត់យ៉ាងច្បាស់លាស់ ក្នុងជំពូកទី ៣ ស្ដីពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចាប់ពីមាត្រា ៣១ ដល់មាត្រា ៥០ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[25]

សរុបសេចក្ដីមក “ **សញ្ជាតិខ្មែរ** ” គឺជាទីកន្លែងកំណើត ឬជាទីដើមកំណើតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានពណ៌ សម្បុរ រូបរាងកាយ សាច់ឈាម ព្រមទាំងមានអត្តសញ្ញាណជាតិ ដូចជា សំបុត្របញ្ជាក់ពីកំណើត ឬលិខិតនានា ដោយពុំគិតពីការរស់នៅឯបរទេស ឬនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ ការផ្ដល់សញ្ជាតិខ្មែរពីរដ្ឋផ្ទាល់ តាំងពីរូបវន្តបុគ្គលចាប់កំណើតមក និងរស់នៅ ដោយមិនគិតពីទីណាកន្លែង ដែលបានកំណត់អំពីលក្ខខណ្ឌនៃការទទួលបានសញ្ជាតិនៅក្នុងច្បាប់ស្ដីពីសញ្ជាតិឆ្នាំ

[22] យោងតាមមាត្រា ៤ នៃច្បាប់ស្ដីពីសញ្ជាតិឆ្នាំ២០១៨

[23] យោងតាមមាត្រា ២១ នៃក្រមរដ្ឋប្បវេណីសង្គមចាស់ឆ្នាំ១៩៦៧

[24] យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្ដីពីការអនុវត្តច្បាប់ស្ដីពីសញ្ជាតិ

[25] យោងតាមជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២០១៨ មានវិសាលភាពទៅដល់រូបវន្តបុគ្គលកើត ឬរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ដោយយោងទៅតាមមាត្រា ៣ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨។[26] រដ្ឋត្រូវតែមានតួនាទីផ្តល់សិទ្ធិ កាតព្វកិច្ច និងការពារទៅដល់ប្រជាពលរដ្ឋតាមរយៈចំណងខាងផ្លូវចិត្ត ផ្លូវគតិយុត្ត និងផ្លូវនយោបាយ ដោយសារតែប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនារបស់ប្រទេសជាតិ ហើយអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋខ្មែរ និងគ្រប់ប្រជាពលរដ្ឋខ្មែរប្រើអំណាចតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តីដោយយោងទៅតាមមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[27] **ឧទាហរណ៍** : សញ្ជាតិអាមេរិក គឺជាសញ្ជាតិផ្តាច់មុខរបស់ប្រទេសអាមេរិក ដែលមានរដ្ឋមានបុព្វសិទ្ធិធ្វើការប្រគល់ ឬប្រទានសញ្ជាតិជាប្រជាពលរដ្ឋអាមេរិក។ ប៉ុន្តែពលរដ្ឋអាមេរិកពុំមានសិទ្ធិប្រគល់សញ្ជាតិ អាមេរិករបស់ខ្លួន បន្តទៅឲ្យបុគ្គលណាម្នាក់ផ្សេងទៀតបានឡើយ។

រីឯពាក្យថា “***រូបវន្តបុគ្គល***” គឺជាពាក្យបច្ចេកទេសសម្រាប់សម្គាល់ទៅលើបុគ្គលម្នាក់ៗ ឬពលរដ្ឋម្នាក់ៗដែលរស់នៅក្នុងប្រទេសមួយ ដែលបញ្ជាក់ពីអត្ថិភាពនៃបុគ្គលភាពគតិយុត្ត។ ជាពិសេស យើងអាចកំណត់ចំពោះរូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើតហើយបាត់បង់អស់នូវសមត្ថភាពទទួលបានសិទ្ធិនេះនៅពេលទទួលមរណភាព ដោយយោងតាមមាត្រា ៨ នៃច្បាប់រដ្ឋប្បវេណីឆ្នាំ២០០៧។[28]

បើយោងតាមសន្ធានុក្រមច្បាប់វិញ “***រូបវន្តបុគ្គល***” គឺជាបុគ្គលដែលមានរូបពិតៗផ្ទុយនឹង នីតិបុគ្គលដែលជាមនុស្សដោយសន្មតិតាមរបៀបច្បាប់ ឬមនុស្សពិតតាមធម្មជាតិដែលផ្ទុយនឹងនីតិបុគ្គលស្របទៅតាមមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។[29] ម៉្យាងវិញទៀតរូបវន្តបុគ្គលត្រូវបានការពារឡើងដោយច្បាប់តាំងពីអាយុ ៣ខែ នៅក្នុងផ្ទៃពោះរបស់ម្តាយដោយម្តាយមិនមានសិទ្ធិរំលូតកូនចោលឡើយ។ ហេតុដូច្នេះរដ្ឋមានតួនាទីការពាររូបវន្តបុគ្គល តាំងពីអាយុលើសពី ១២សប្តាហ៍ ដោយយោងតាមមាត្រា ៨ នៃច្បាប់ស្តីពីការរំលូតកូនឆ្នាំ១៩៩៧។[30] ជាពិសេស លក្ខណៈ ដែលអាចសម្គាល់ទៅលើរូបវន្តបុគ្គលបាន លុះត្រាតែ មនុស្សគ្រប់រូបជារូបវន្តបុគ្គល គ្រប់រូបវន្តបុគ្គលសុទ្ធតែមានបុគ្គលិកលក្ខណៈគតិយុត្ត បុគ្គលិកលក្ខណៈគតិយុត្តជាលក្ខណៈសម្បត្តិដែលអាចទទួលបាននូវសិទ្ធិ និង កាតព្វកិច្ចតាមផ្លូវច្បាប់ អត្ថិភាពនៃបុគ្គលិកលក្ខណៈគតិយុត្តរបស់មនុស្សម្នាក់ត្រូវបានផ្តល់ដោយច្បាប់ដែលចាប់ផ្តើមមានពីពេលចាប់កំណើតរហូតដល់បញ្ចប់ទៅវិញនៅពេលមរណភាព មនុស្សគ្រប់រូបចាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញ ដោយត្រូវបានចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ចំពោះព្រឹត្តិការណ៍សំខាន់ៗ ០៣ (បី) គឺ៖

[26] យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[27] យោងតាមមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[28] យោងតាមមាត្រា ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[29] យោងតាមមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[30] យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីរំលូតកូនឆ្នាំ១៩៩៧

កំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដោយយោងតាមមាត្រា ៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០[31] ដែលហៅថាព្រឹត្តិការណ៍គតិយុត្ត ព្រឹត្តិការណ៍គតិយុត្ត គឺជាអំពើ ឬព្រឹត្តិការណ៍ដែលនាំឱ្យកើត ឬបង្អង់ ឬរំលត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់រូបវន្តបុគ្គល។

សរុបសេចក្តីមក "**រូបវន្តបុគ្គល**" ជាវាក្យស័ព្ទសម្រាប់បញ្ជាក់ពីបុគ្គលម្នាក់ៗដែលកើតមករស់ ហើយនឹងអាចរស់បាន ត្រូវតែបានទទួលអត្តសញ្ញាណជាតិតាំងពីកំណើតដោយរដ្ឋជាអ្នកផ្តល់នូវសញ្ជាតិទៅដល់បុគ្គលនោះ ដោយស្របទៅតាមច្បាប់ស្តីពីសញ្ជាតិរបស់ប្រទេស ព្រមទាំងត្រូវបានការពារដោយច្បាប់នៃប្រទេសផងដែរ។ ជាពិសេស គេអាចចាត់ទុកជារូបវន្តបុគ្គលបានលុះត្រាតែគោរពទៅតាមលក្ខខណ្ឌ ពីរ យ៉ាង គឺ ក្មេងកើតមករស់នៅ និងក្មេងនោះនឹងអាចរស់នៅបាន ហើយត្រូវទទួលបានសិទ្ធិ និងកាតព្វកិច្ចផងដែរ។

**កថាខណ្ឌទី២ ធាតុផ្សំនៃអត្តសញ្ញាណរបស់រូបវន្តបុគ្គល**

ធាតុផ្សំនៃអត្តសញ្ញាណរបស់រូបវន្តបុគ្គលគ្រប់រូប គឺត្រូវផ្សំឡើងតាមរយៈឈ្មោះ លំនៅដ្ឋាន សញ្ជាតិ និងជនអន្តោប្រវេសន៍ ឬវិនិយោគិន ដែលបានមកពីការទទួលបាន និងផ្តល់សញ្ជាតិពីរដ្ឋខ្មែរ។ លក្ខណៈដែលអាចសម្គាល់ថាជារូបវន្តបុគ្គលបាន លុះត្រាតែមាន៖

-**ឈ្មោះ ៖** មនុស្សគ្រប់រូបដែលកើតនៅលើផែនដី គឺត្រូវតែមានឈ្មោះជាចាំបាច់។ ទើបអាចសម្គាល់រូបវន្តបុគ្គលនោះជាអ្នកណា ឬជាតិសាសន៍បាន។ ឈ្មោះមានលក្ខណៈមិនប្រែប្រួល ហើយជាប់លាប់ និងគ្មានអាជ្ញាយុកាលឡើយ។ មនុស្សកើតមកត្រូវតែមានឈ្មោះដោយកំណត់ទៅតាម ពីររបៀបគឺ៖

**១ តាមរយៈបុគ្គភាព ៖** គ្រប់រូបវន្តបុគ្គលដែលកើតមកត្រូវតែដាក់ឈ្មោះឱ្យរូបវន្តបុគ្គលនោះជាចាំបាច់ ដោយយកនាមត្រកូលរបស់ទារកអាចយកត្រកូលដែលក្រុមគ្រួសារជាអ្នកកំណត់យកតាមដូនតាយូរលង់មកហើយ ឬអាចយកឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកក៏បាន ឬក៏អាចដាក់នាមត្រកូលឪពុកម្តាយផ្ទាល់ក៏បាន យោងតាមមាត្រា ១៨ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០។[32] ដូច្នេះ ត្រូវតែគោរពទៅតាមលក្ខខណ្ឌដូចជា គឺ

**- កូនមានខាន់ស្លា ៖** នាមត្រកូលត្រូវយកត្រកូលដែលក្រុមគ្រួសារបានកំណត់យកតាំងពីដូនតា ឬយកឈ្មោះតាមជីតារបស់ឪពុក ឬឈ្មោះឪពុកផ្ទាល់ក៏បាន។

**- កូនឥតខាន់ស្លា ៖** បើឪពុកម្តាយទទួលស្គាល់ទាំងពីរ គឺត្រូវយកនាមត្រកូលខាងឪពុក។ ប៉ុន្តែប្រសិនបើមានតែឪពុក ឬម្តាយទទួលស្គាល់តែម្ខាង នាមត្រកូលនោះត្រូវតែយកតាមនាមត្រកូលអ្នកដែលទទួលស្គាល់ជាកូន។

**- កូនសុំពេញលេញ ៖** ត្រូវតែយកនាមត្រកូលទៅតាមឪពុក ឬម្តាយចិញ្ចឹម ឬអ្នកដែលបានសុំកូននោះ។

[31] យោងតាមមាត្រា ៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[32] យោងតាមមាត្រា ១៨ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

**២ តាមរយៈអាពាហ៍ពិពាហ៍ ៖** នៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ គ្រប់សហព័ន្ធ មិនថា អ្នកមាន ឬអ្នកក្រ ឬអ្នកធំ ឬអ្នកតូច សុទ្ធតែអាចផ្លាស់ប្តូរឈ្មោះ ឬប្តូរនាមត្រកូលរបស់ខ្លួនទៅតាមប្តី ឬប្រពន្ធ ឬប្រើប្រាស់នាមត្រកូលរៀងៗខ្លួនបាន ឬក៏អាចបន្ថែមឈ្មោះរបស់ប្តីឬប្រពន្ធនៅខាងចុងក្រោយនៃឈ្មោះរបស់ប្តីឬប្រពន្ធបាន។

-**លំនៅឋាន ៖** ជាកន្លែងជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ដោយយោងតាមមាត្រា ៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។[33] ចំណែកឯទីសំណាក់វិញ ក្នុងករណីដែលកន្លែងជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន យោងតាមមាត្រា ៣៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។[34] ជាពិសេស លក្ខណៈដែលអាចសម្គាល់ជាលំនៅឋានបាន លុះត្រាតែរូបវន្តបុគ្គលមួយក្រុមនោះ ត្រូវតែរស់នៅជាមួយគ្នាក្រោមដំបូលផ្ទះតែមួយ។ ចំពោះក្នុងករណីដែលរូបវន្តបុគ្គលគ្មានទីលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន យោងតាមមាត្រា ៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។[35] ប៉ុន្តែ ក្នុងបញ្ញត្តិនេះ មិនត្រូវបានអនុវត្តចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្តឡើយ។ លំនៅឋានរបស់មនុស្សម្នាក់ៗ គឺជាកន្លែងដែលអ្នកនោះបានកំណត់ការស្នាក់នៅរបស់ខ្លួន ជាទម្លាប់របស់គេ ហើយជាទីតាំងដ៏សំខាន់នៃកិច្ចការ និងជីវភាពរស់នៅរបស់គេជាប្រចាំ។ លំនៅឋានត្រូវកំណត់យកតែមួយគត់ ព្រោះជាកន្លែងដែលភ្ជាប់បុគ្គលិកលក្ខណៈគតិយុត្តនៃរូបវន្តបុគ្គលទៅនឹងលំនៅឋាននោះ។ ក្នុងករណីដែលគេមិនអាចកំណត់លំនៅឋានរបស់បុគ្គលណាម្នាក់បានច្បាស់លាស់ទេនោះ គេត្រូវកំណត់យកទីសំណាក់ ឬនិវេសនដ្ឋានណាមួយរបស់អ្នកនោះថាជាលំនៅឋានរបស់បុគ្គលជាចំបង។

ការកំណត់លំនៅឋានច្បាស់លាស់របស់បុគ្គលម្នាក់ គឺបានផ្តល់ភាពងាយស្រួលក្នុងរឿងក្តីរដ្ឋប្បវេណី។ **ឧទាហរណ៍** ដូចជាតុលាការមានសមត្ថកិច្ច គឺតុលាការនៃទីលំនៅរបស់ចុងចម្លើយ។ ចំពោះអាពាហ៍ពិពាហ៍ត្រូវរៀបចំឡើងនៅខាងលំនៅឋានរបស់ភាគីខាងនារី។

-**សញ្ជាតិ** គឺជាចំណងគតិយុត្តទាំងខាងផ្លូវចិត្ត ផ្លូវច្បាប់ និងនយោបាយដែលបានផ្សារភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមមាត្រា ៤ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨[36] និងត្រូវអនុវត្តទៅតាមអនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពី ការអនុវត្តច្បាប់សញ្ជាតិ ឆ្នាំ២០១៨ នេះផងដែរ។

ចំណែកការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេសនិងពលរដ្ឋខ្មែរវិញ ដោយត្រូវផ្អែកទៅលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់ខ្លួនរបស់សាមីខ្លួន និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិត

[33] យោងតាមមាត្រា ៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[34] យោងតាមមាត្រា ៣៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[35] យោងតាមមាត្រា ៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[36] យោងតាមមាត្រា ៤ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

បទដ្ឋានពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមមាត្រា២ នៃអនុក្រឹត្យលេខ១១២អនក្រ.បកស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨។[37]

**-ជនបរទេស និងជនអន្តោប្រវេសន៍**

**១ ជនបរទេស** គឺជាជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានការរើសអើង ទោះបីជាជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ដោយយោងតាមមាត្រា ២ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។[38] ទោះបីជាជនបរទេសនោះ ស្ថិតនៅក្រៅប្រទេសកម្ពុជាក្តី ឬកំពុងស្ថិតនៅ ឬស្នាក់នៅក្នុងប្រទេសកម្ពុជាក្តីក្នុងរយៈពេលខ្លី។ **ឧទាហរណ៍** លោកស្រី Jack Ma ជាជនបរទេសមានសញ្ជាតិចិន ដោយគាត់បានមកធ្វើទស្សនកិច្ចនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជារយៈពេល ២សប្តាហ៍ ដោយមកទស្សនាទីក្រុងអង្គរពីបុរាណ និងប្រាង្គប្រាសាទបុរាណផ្សេងទៀតផងដែរ។

**២ ជនបរទេសកំពុងស្ថិតនៅ ឬស្នាក់នៅកម្ពុជា** គឺត្រូវបានអនុលោមតាមលក្ខខណ្ឌនៃប្រវេសន៍ និងការស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ជនបរទេសត្រូវចែកជា បីប្រភេទគឺ ជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន ដោយយោងតាមមាត្រា ៤ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។[39]

**២.១ ជនបរទេសមិនមែនអន្តោប្រវេសន៍**

ជនបរទេសមិនមែនអន្តោប្រវេសន៍ ដោយយោងតាមមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ [40] គឺជា ៖

- ភ្នាក់ងារដែលបំរើការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុលបរទេស ឬស្ថានតំណាងបេសកកម្មបរទេស អ្នកជំនាញការអន្តរជាតិ និងជនផ្សេងៗដែលចូលមកព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយរាប់ទាំងក្រុមគ្រួសារ និងបុគ្គលិករបស់គេក្នុងរយៈពេលដែលគេស្នាក់អាស្រ័យនៅ។

- ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិក និងភ្នាក់ងារបរទេស និស្សិត ព្រមទាំងគ្រួសារដែលចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

- អ្នកធ្វើដំណើរឆ្លងកាត់ ជាអ្នករង់ចាំមធ្យោបាយធ្វើដំណើរមុនពេលចេញដំណើរឆ្ពោះទៅកាន់ទីលំនៅចុងក្រោយរបស់ខ្លួន។ ក្នុងករណីនេះ ការស្នាក់អាស្រ័យនៅមិនត្រូវលើសពីមួយសប្តាហ៍លើកលែងតែក្នុងករណីប្រធានសក្តិ។

- អ្នកតំណាងពាណិជ្ជកម្ម ធនាគារ អ្នកប្រកបមុខរបរផ្សេងៗទៀត ដែលចូលព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យមិន

[37] យោងតាមមាត្រា ២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[38] យោងតាមមាត្រា២ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[39] យោងតាមមាត្រា៤ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[40] យោងតាមមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

អាចលើសពី ៣ខែ។ ក្នុងករណីមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យនៅនេះ អាចបន្តទៀតបាន រយៈពេល ៣ខែ ជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

- ជនបរទេសរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ដែលបាន ទទួលការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល។ លក្ខខណ្ឌផ្សេងៗក្នុងការ អនុវត្តចំណុច៦ មាត្រា៧ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។[41]

- អ្នកធ្វើដំណើរ កងនាវិក និងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាម ព្រលានយន្តហោះ។

- ជនបរទេសដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមាន ការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

### ២.២ ជនបរទេសអន្តោប្រវេសន៍

ជនបរទេសអន្តោប្រវេសន៍ គឺជាជនបរទេសដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដោយស្រប ច្បាប់ ដើម្បីស្នាក់នៅរយៈពេលយូរ ឬដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹង ឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម និងជាជនដែលមិនមានរាប់ចូលក្នុងប្រភេទណាមួយ ដូច មានចែងក្នុងមាត្រា៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ឡើយ។[42]

### ២.៣ ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន

ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន គឺជាជនបរទេសដែលចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើវិនិយោគក្នុងក្របខ័ណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។[43]

ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន ចែកចេញជា ពីរប្រភេទ ជនបរទេសដែល ចូលមកកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ និងជនបរទេសដែលបានទទួល " **លិខិតអនុញ្ញាតឱ្យ វិនិយោគ** " ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ។[44]

## ៣ ការចេញ ចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេស

### ៣.១ ជនបរទេសមិនមែនអន្តោប្រវេសន៍

ជនបរទេសមិនមែនអន្តោប្រវេសន៍ទាំងឡាយណា ដែលមានបំណងចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈអាជ្ញាធរទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬច្រកទ្វារអន្តរជាតិ ឬតាមគេហទំព័រទិដ្ឋាការ អេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ ដោយយោងតាមមាត្រា ៤ នៃអនុក្រឹត្យ១២៣ អនក្រ.បក ស្តីពី

[41] យោងតាមមាត្រា ៦ និងមាត្រា៧ នៃច្បាប់ស្តីពីជនអន្តោប្រវេសន៍

[42] យោងតាមមាត្រា១០ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[43] យោងតាមមាត្រា២៥ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[44] យោងតាមមាត្រា២៦ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣។[45] ព្រមទាំងមានកំណត់នីតិវិធី និងបែបបទ នៅក្នុងមាត្រា ៦ ៧ និង៨ នៃអនុក្រឹត្យ១២៣ អនក្រ.បក ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣។[46]

### ៣.២ ជនបរទេសអន្តោប្រវេសន៍

ជនបរទេសអន្តោប្រវេសន៍ដែលមានបំណងមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំមកក្រសួងមហាផ្ទៃបាន តាមរយៈអាជ្ញាធរទូត ឬកុងស៊ុល ឬតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេស។

ការទទួលស្គាល់ជនបរទេសណាមួយ ជាជនបរទេសអន្តោប្រវេសន៍ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។ ជនបរទេសដែលត្រូវទទួលស្គាល់ជាជនបរទេសអន្តោប្រវេសន៍ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅ នៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលខេត្តក្រុងក្នុងរយៈពេល ៤៨ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា។ ព្រមទាំងគោរពទៅតាមពីមាត្រា១១ដល់២៤ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលបញ្ជាក់ពីទិដ្ឋាការនៃការស្នាក់នៅ និងការចេញពីព្រះរាជាណាចក្រកម្ពុជា។[47]

### ៣.៣ ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគ

ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ ត្រូវបំពេញល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងជំពូកទី ៣ ស្តីពីជនបរទេសអន្តោប្រវេសន៍ លើកលែងតែសុពលភាពសម្រាប់រយៈពេលស្នាក់នៅបណ្តោះអាសន្ន គឺសម្រាប់រយៈពេលមួយឆ្នាំ។ ក្រោយរយៈពេលមួយឆ្នាំនៃការស្នាក់នៅ ក្នុងករណីដែលមិនអាចមានលទ្ធភាពធ្វើវិនិយោគបានលើវិស័យណាមួយទេ ជនបរទេសនោះអាចដកប្រាក់តម្កល់នានាវិញបាន ហើយមិនអាចបន្តឱ្យស្នាក់នៅបានទៀតឡើយ ដោយយោងតាម ២៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។[48] ជនបរទេសដែលបានទទួលបាន **លិខិតអនុញ្ញាតឱ្យវិនិយោគ** ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួមទាំងគ្រួសារផ្ទាល់ខ្លួន នឹងបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគ និងមានសិទ្ធិសុំកាន់ឯកសារធ្វើដំណើររបស់ព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមមាត្រា

---

[45] ដោយយោងតាមមាត្រា ៤ នៃអនុក្រឹត្យ១២៣ អនក្រ.បក ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣

[46] ដោយយោងតាមមាត្រា ៦, ៧ និង៨ នៃអនុក្រឹត្យ១២៣ អនក្រ.បក ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣

[47] ដោយយោងតាមមាត្រា ១១ ដល់២៤ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[48] ដោយយោងតាមមាត្រា ២៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

២៨ នៃច្បាប់ស្តីពីអន្តោប្រវេសន៍។[49] ការទទួលស្គាល់ជនបរទេសណាមួយថា ជាជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។ ជនបរទេសដែលបានទទួលលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគ ព្រមទាំងគ្រួសារផ្ទាល់អាចស្នាក់នៅជាអចិន្ត្រៃយ៍ ឬតាមរយៈដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានទទួលប័ណ្ណស្នាក់នៅចេញឱ្យដោយក្រសួងមហាផ្ទៃ។

**ផ្នែកទី២ ការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល**

យោងតាមច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨ បានកំណត់ទៅលើលក្ខខណ្ឌ ដែលអាចទទួលបានសញ្ជាតិខ្មែរបាន ក្នុងករណី ០៤ ធំៗគឺ ៖

១. ការទទួលបានសញ្ជាតិខ្មែរពីកំណើត

២. ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ

៣. ការទទួលបានសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍

៤. ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម។[50]

ហើយគ្រប់រូបវន្តបុគ្គលដែលទទួលបានសញ្ជាតិខ្មែរតាមរយៈការផ្តល់ និងការទាមទារ ក៏អាចសុំបោះបង់ ឫលះបង់សញ្ជាតិខ្មែរបានផងដែរ ដោយមានការកំណត់អាយុយ៉ាងតិច ១៨ឆ្នាំឡើងទៅ និងដោយពុំមានការបង្ខិតបង្ខំឡើយ។[51]

**កថាខណ្ឌទី១ លិខិតបទដ្ឋានគតិយុត្ត**

គ្រប់លិខិតបទដ្ឋានគតិយុត្តកំពូលដែលទាក់ទងនឹងច្បាប់ ស្តីពី សញ្ជាតិខ្មែរ ដោយកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី២ ដោយបានកំណត់ពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ បន្ទាប់មកក៏បានបង្កើតច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃ១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំអង្គលើកទី១ នីតិកាលទី៤ ដោយបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងជំនួសដោយច្បាប់ថ្មីនេះ។ ក្រោយមកក៏មានការបង្កើតអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ ដោយយោងតាមមាត្រា ១ ដែលបានកំណត់ពីគោលបំណងធានាការអនុវត្តបែបបទ និងនីតិវិធីក្នុងការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសដែលមាន

[49] ដោយយោងតាមមាត្រា ២៨ នៃច្បាប់ស្តីពីអន្តោប្រវេសន៍

[50] យោងតាមមាត្រា២ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

[51] យោងតាមមាត្រា២៨ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

ចំណោងអាពាហ៍ពិពាហ៍របស់ជនបរទេសដែលមានចំណង អាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ បែបបទ និងនីតិវិធីក្នុងការសុំចូលសញ្ជាតិខ្មែររបស់ជន បរទេសដោយសញ្ជាតូបនីយកម្ម និងបែបបទ និងនីតិវិធីក្នុងការសុំលះបង់សញ្ជាតិខ្មែររបស់ពលរដ្ឋខ្មែរដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំ។[52] លើសពីនេះទៅទៀត ក៏មានលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលទាក់ទងផងដែរ ដោយយោងតាមឧបសម្ព័ន្ធ និងឯកសារយោងផងដែរ។

**កថាខណ្ឌទី២ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល**

**១ ការទទួលបានសញ្ជាតិខ្មែរពីកំណើត**

គ្រប់រូបវន្តបុគ្គល គឺត្រូវតែរួមផ្សំឡើងដោយប្រជាជាតិ និងជនបរទេសទាំងឡាយដែលបានរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវតែមានសញ្ជាតិខ្មែរដាច់ខាត។ ការទទួលបានសញ្ជាតិខ្មែររបស់រូបវន្តបុគ្គលត្រូវតែស្របទៅតាមច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ ដែលជំនួសដោយច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ១៩៩៦ចាស់។

កំណើត គឺជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គល ពោលគឺជាការចាប់ផ្តើមមកកើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។

**ដើម្បីឱ្យបានក្លាយជារូបវន្តបុគ្គលនិងអាចទទួលបានសញ្ជាតិខ្មែរដោយមានសិទ្ធិនិងកាតព្វកិច្ចពេញលេញត្រូវស្របទៅតាមលក្ខខណ្ឌ ពីរយ៉ាង គឺ៖**

**-កើតមកជាមនុស្ស**: គ្រប់រូបវន្តបុគ្គលដែលកើតនៅក្នុងប្រទេស ត្រូវតែមានរូបរាង ឬកាយសម្បទាគ្រប់គ្រាន់ ទៅតាមលក្ខណៈសម្បត្តិរបស់មនុស្ស។

ឧទាហរណ៍ ៖ មានសាច់ ឈាម រូបរាង ភ្នែក ច្រមុះ ត្រចៀក ឈ្មោះ ទីលំនៅ ជាដើម ។

**-កើតមករស់ ហើយនឹងអាចរស់បាន**: រូបវន្តបុគ្គលគ្រប់រូបត្រូវតែកើតមករស់នៅ តាមធម្មតា ហើយបើកើតមកស្លាប់ ឬមានជម្ងឺតាំងពីនៅក្នុងពោះ ដោយមិនអាចរស់បាន គឺមិនអាចចាត់ទុកជារូបវន្តបុគ្គលបានឡើយ។ ដូច្នេះក៏មិនអាចទទួលបានសញ្ជាតិផងដែរ។

ឧទាហរណ៍ ៖ កុមារដែលកើតមកភ្លាមស្លាប់ភ្លាមនៅពេលដែលម្តាយឆ្លងទន្លេ ឬនៅពេលកើតមកហើយដែលមានជម្ងឺមិនអាចនឹងរស់បានដោយមានបញ្ជាក់ពីមន្ទីរពេទ្យផងដែរ។

**លក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិខ្មែរពីកំណើត**

**ដោយស្របទៅតាមលក្ខខណ្ឌច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨[53] បានកំណត់ថា ៖**

**១ ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ៖**

[52] យោងតាមមាត្រា ១ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

[53] យោងតាមមាត្រា៩ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

-**កូនដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ** គឺជាកូនកើតមកពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ។ បើទោះបីជាកូននោះ មានខាន់ស្លាក្តី ឬឥតខាន់ស្លាក្តី ត្រូវតែទទួលបានសញ្ជាតិខ្មែរដោយការទាមទារពីរដ្ឋ ដោយកំណត់ដោយច្បាប់ ឬ

-**កូនដែលឪពុកម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ** គឺកូនដែលឪពុក ឬម្តាយមិនទទួលស្គាល់ ហើយត្រូវបានបោះបង់ចោល តុលាការមានតួនាទីជាអ្នកតំណាង ឬតតិយជនជាអ្នកតំណាងរបស់រូបវន្តបុគ្គល ដែលច្បាប់បានកំណត់ដើម្បីទាមទារនូវសិទ្ធិទទួលបានសញ្ជាតិខ្មែរ បើទោះបីជាកូននោះជាជនបរទេសក្តីដោយឪពុក ឬម្តាយបានបោះបង់ចោលនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

**២ ត្រូវបានសញ្ជាតិខ្មែរ ដោយកើតក្នុងព្រះរាជាណាចក្រកម្ពុជា ៖**

-**កូនដែលកើតពីឪពុកនិងម្តាយជាជនបរទេសដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ៖** ជាកូនដែលកើតឡើងពីឪពុក និងម្តាយដែលមានសញ្ជាតិបរទេសហើយបានស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងលក្ខខណ្ឌណាមួយក៏ដោយ កូននោះត្រូវតែទទួលបានសញ្ជាតិខ្មែរស្របទៅច្បាប់កំណត់។

-**កូនដែលកើតពីឪពុកនិងម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ។**

**ឧទាហរណ៍** ៖ ទារក **ក** ដែលទើបនឹងកើត ឬកើតយូរថ្ងៃ ត្រូវបានគេបោះបង់ចោល និងទុកចោលនៅមុខអង្គការសុវណ្ណកុមារកម្ពុជា មិនថាកូននោះជាជនជាតិអ្វីក៏ដោយ ក៏ប្រធានអង្គការមានតួនាទីធ្វើជាអ្នកតំណាងរបស់ទារក ដើម្បីរាយការណ៍ជូនដល់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានដឹង ក្នុងការស្វែងរក នីតិវិធីចំពោះទារក ស្វែងរកសាច់ញាតិ ឬទាមទារសញ្ជាតិខ្មែរពីតុលាការផងដែរ។

**គេក៏អាចសម្គាល់ទៅលើរូបវន្តបុគ្គលដែលអាចចូលសញ្ជាតិខ្មែរពីកំណើតបាន តាមរយៈ ពីរយ៉ាងគឺ ៖**

**១ ឈាមជ័រ ឬខ្សែលោហិត ៖** ចំពោះករណីនេះ ច្បាប់ខ្មែរ ក៏ដូចជា ច្បាប់នៅតាមប្រទេសភាគច្រើនផ្សេងទៀតនៅលើពិភពលោកជាពិសេសប្រទេសដែលមានប្រព័ន្ធច្បាប់Romano-Germanique ការកំណត់សញ្ជាតិខ្មែរពីកំណើត គឺត្រូវតែយកសិទ្ធិដែលជាប់នឹងខ្សែលោហិតជាធំ។ មានន័យថា កូនដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើត ទោះបីជាកើតនៅទីណាក៏ដោយ(កើតនៅក្នុងទឹកដីកម្ពុជាក៏ដោយ ឬក៏កើតនៅបរទេសក៏ដោយ)។ គួរបញ្ជាក់ដែលថា មិនចាំបាច់តែឪពុកម្តាយទាំងពីរដែលមានសញ្ជាតិខ្មែរឡើយ ឱ្យតែកូននោះមានឪពុក ឬម្តាយមានសញ្ជាតិខ្មែរពីកំណើត ក៏កូននោះអាចទទួលបានសញ្ជាតិពីកំណើតដែរ។ ម្យ៉ាងវិញទៀត ទោះបីជាកូនមានខាន់ស្លាក្តី(ឪពុក និងម្តាយមានចំណងអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់កំណត់) ឬកូនឥតខាន់ស្លាក្តី (កូនកើតមកដែលមានឪពុក និងម្តាយពុំមានចំណងគតិយុត្តអាពាហ៍ពិពាហ៍ឡើយ) ដោយមានម្តាយ ឬ

ឪពុកមានសញ្ជាតិខ្មែរ ក៏អាចទទួលបានសញ្ជាតិខ្មែរពីកំណើតបានដែរ ឱ្យតែឪពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ ទទួលស្គាល់កូននោះថាជាកូនរបស់ខ្លួន។

**ឧទាហរណ៍ ៖** កូនកើតក្រៅចំណងអាពាហ៍ពិពាហ៍ ពីម្តាយជាជនបរទេស ហើយឪពុកមានសញ្ជាតិខ្មែរ។ ប្រសិនបើជាឪពុកដែលមានសញ្ជាតិខ្មែរនេះ ទទួលស្គាល់តាមផ្លូវច្បាប់ថា កូននោះ គឺជាកូនរបស់ខ្លួន កូននោះគឺជាកូនរបស់ខ្លួន ហើយត្រូវមានសិទ្ធិទទួលបានសញ្ជាតិខ្មែរពីកំណើតផងដែរ។ ផ្ទុយទៅវិញ បើមានតែម្តាយជាជនបរទេសដែលទទួលស្គាល់កូន ចំណែកឪពុកមិនទទួលស្គាល់ កូននោះមិនអាចទទួលបានសញ្ជាតិខ្មែរពីកំណើតបានទេ ព្រោះម្តាយមិនមានសញ្ជាតិខ្មែរ។ ក្នុងករណីនេះ កូនដែលឪពុកម្តាយមិនទទួលស្គាល់ ប៉ុន្តែតុលាការចេញសាលក្រមកំណត់ថា កូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ កូននេះក៏ត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើតដែរ។

**២ តាមទីកន្លែងកំណើត ៖** ត្រូវទទួលបានសញ្ជាតិខ្មែរចំពោះកូនដែលកើតននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះកូនបរទេស ដែលមានឪពុកម្តាយជាជនជាតិបរទេសកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវទទួលបានសញ្ជាតិខ្មែរផងដែរ។ ច្បាប់ខ្មែរមិនដូចជាច្បាប់នៅប្រទេសមួយចំនួនដូចជា អាមេរិក កាណាដា ឬក៏អូស្ត្រាលីឡើយ ពីព្រោះកូនដែលកើតនៅលើទឹកដីខ្មែរ ដោយឪពុក ឬម្តាយជាជនជាតិបរទេស មិនអាចទទួលបានសញ្ជាតិខ្មែរពីកំណើតឡើយ លុះត្រាតែឪពុក ឬម្តាយជាជនបរទេសនោះ កើតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយនឹងរស់នៅស្របទៅតាមច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ទើបកូននោះអាចទទួលបានសញ្ជាតិខ្មែរពីកំណើតបាន។

សរុបមកវិញកូនដែលកើតនៅលើទឹកដីខ្មែរពីឪពុកម្តាយជាជនបរទេស ហើយឪពុកម្តាយបរទេសនោះមិនបានកើតនៅក្នុងប្រទេសកម្ពុជាទេ កូននោះក៏មិនអាចទទួលបានសញ្ជាតិខ្មែរពីកំណើតបានទេ។ ក៏ប៉ុន្តែប្រសិនបើកូននោះកើតមកធំដឹងក្តី បន្តរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ហើយក្រោយមកមានកូនកើតនៅក្នុងប្រទេសកម្ពុជា កូននោះនឹងត្រូវមានសិទ្ធិទទួលបានសញ្ជាតិខ្មែរពីកំណើត។

ដូច្នេះ គ្រប់រូបវន្តបុគ្គលដែលកើតមកនៅក្នុងប្រទេសមួយត្រូវតែបានទទួលសញ្ជាតិមួយជាចាំបាច់ទោះបីជាជនជាតិអ្វីក៏ដោយឱ្យតែបានស្នាក់នៅក្នុងប្រទេសកម្ពុជាដោយស្របច្បាប់ ទើបរូបវន្តបុគ្គលជំនាន់ទី២ ត្រូវតែទទួលបានសញ្ជាតិពីកំណើត ដោយរដ្ឋតាមរយៈការធ្វើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតពីមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ ដែលឪពុក ឬម្តាយខ្មែរបានស្នាក់នៅអចិន្ត្រៃយ៍ដោយស្របច្បាប់។ សបញ្ជាក់ឱ្យឃើញថារូបវន្តបុគ្គលជំនាន់ទី២នោះ ពិតជាមានសញ្ជាតិខ្មែរយ៉ាងពេញលេញ និងពិតប្រាកដស្របទៅតាមច្បាប់កំណត់។ ការទទួលបានសញ្ជាតិខ្មែរនោះផងដែរ គឺត្រូវតែមានជាប់កាតព្វកិច្ច និងសិទ្ធិរបស់រូបវន្តបុគ្គលដែលត្រូវធ្វើផងដែរ ដោយស្របទៅតាមលក្ខខណ្ឌនៃច្បាប់សញ្ជាតិខ្មែរឆ្នាំ២០១៨[54]។

[54] យោងតាមមាត្រា៩ នៃច្បាប់ស្តីពីសញ្ជាតិខ្មែរ

រូបវន្តបុគ្គលទាំងឡាយណាដែលអាចនឹងទទួលបានសញ្ជាតិខ្មែរ លុះត្រាតែរូបវន្តបុគ្គលទាំងនោះ បានបំពេញតាមលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិទុកជាមុន។

ដូច្នេះ រូបវន្តបុគ្គលដែលត្រូវទទួលបានសញ្ជាតិខ្មែរពីកំណើត ទោះបីកើតនៅទីណាក៏ដោយ គឺកូនដែលមានឪពុក ឬម្ដាយមានសញ្ជាតិខ្មែរ និងកូនដែលមានឪពុកម្ដាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្ដាយ ដែលមានសញ្ជាតិខ្មែរ ។

រូបវន្តបុគ្គលដែលមានសិទ្ធិទទួលបានសញ្ជាតិខ្មែរត្រូវតែជាកូនកើតចេញពីឪពុក និងម្ដាយជាជនបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬកូនដែលកើតពីឪពុកម្ដាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការទទួលបានសញ្ជាតិខ្មែរតាមរយៈទីកន្លែងកំណើតគឺត្រូវបានទទួលស្គាល់ដោយច្បាប់សញ្ជាតិខ្មែរឆ្នាំ២០១៨។[55] គ្រប់រូបវន្តបុគ្គលដែលកើតនៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែទទួលបានសញ្ជាតិខ្មែរ បើទោះបីជារូបវន្តបុគ្គលនោះមានឪពុក ឬម្ដាយជាជនបរទេសក្ដី អន្តោប្រវេសន៍ក្ដីអ្នកវិនិយោគក្ដី និងជនឆ្លងកាត់ក្ដី កូននោះដែលកើតនៅក្នុងប្រទេសកម្ពុជា ត្រូវតែផ្ដល់ ឬទាមទារសញ្ជាតិទៅឱ្យរូបវន្តបុគ្គលនោះ ដែលកើតមកភ្លាម។

**២ ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ**

ពាក្យថា " សុំកូន " គឺសំដៅដល់ កិច្ចសន្យាដែលបុគ្គលពីរនាក់ ដែលម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ឯម្នាក់ទៀតហៅថា កូនចិញ្ចឹមអោយមានចំណងញាតិនឹងគ្នា ដូចបុត្តភាពខាន់ស្លា។[56] គោលបំណងនៃការបង្កើតអោយមានការសុំកូន គឺដើម្បីបង្កើតជាឧត្តមប្រយោជន៍ដល់កុមារ និងជាតិផងដែរ។

តាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានចែងអំពីរបបនៃការសុំកូនពេញលេញ ( ពីមាត្រា១០០៧ ទៅ)។

**សុំកូនពេញលេញ** គឺជាការសុំកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងតាមផ្លូវតុលាការ ដោយទាមទារឲ្យផ្ដាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្តិ រវាងឪពុកម្ដាយបង្កើត និងញាតិសន្តានរបស់កូនសុំនោះទាំងស្រុង ដើម្បីបង្កើតឲ្យមាននូវទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្ត រវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំនោះវិញ។

ប៉ុន្តែ ការសុំកូនពេញលេញ ក្នុងអត្ថបទនេះមិនមែនជាការសុំកូនពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាយើងទេ គឺជា**ការសុំកូនពេញលេញអន្តរប្រទេស** ដែលមានចែងក្នុងច្បាប់ដោយឡែកមួយទៀត គឺ **ច្បាប់ ស្ដីពី ការសុំកូនអន្តរប្រទេស** ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែ តុលា ឆ្នាំ

[55] យោងតាមមាត្រា៩ នៃច្បាប់ស្ដីពីសញ្ជាតិខ្មែរ

[56] វចនានុក្រម របស់ លោក ភូ ឡាយស្រុន និង លោក ភូ វយចចេង បោះពុម្ពលើកទី១ ឆ្នាំ ២០១២

២០០៩។ ច្បាប់នេះអនុញ្ញាតិឱ្យជនបរទេសធ្វើការសុំកុមារ កម្ពុជា ដើម្បីធ្វើជា កូនពេញសិទ្ធិដូចជាកូនបង្កើតរបស់គេ។ ដូចជាការសុំកូន ដែល អ្នកនាង Angelina Jolie ធ្វើការសុំ កុមារា កម្ពុជា ដែល មានឈ្មោះជាភាសាខ្មែរថា **រតន៍ វិបុល** ( Maddox Chivan Jolie Pit ) ពោលមុនអ្នកនាងអាចធ្វើការសុំកូនបាន អ្នកនាង ត្រូវគោរពទៅតាមលក្ខខណ្ឌដែលមានជាធរមាន ដូចជា ច្បាប់ ស្តីពី ការសុំកូនអន្តរប្រទេស និងច្បាប់ដទៃផ្សេងទៀតដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ប៉ុន្តែបើយើងក្រលេកមើល ទៅលើច្បាប់សញ្ជាតិថ្មី នៃព្រះរាជាណាចក្រកម្ពុជា យើងវិញ យើងឃើញថា **មាត្រា ២ នៃច្បាប់ស្តីពីសញ្ជាតិថ្មី ចំនុច ២ ( ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ )**។[57]

ដែលមានខ្លឹមសារនៅ **មាត្រា ១០** បានចែងថា " **កូនជនបរទេសដែលត្រូវបានសុំជាកូនសុំពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើតឡើងតាមច្បាប់ជាធរមាន** " ។[58]

ដោយឡែក នៅក្នុងចំណុចនេះ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើងបាន អនុញ្ញាតិអោយសហព័ទ្ធពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរទាំងពីរភេទ អាចធ្វើការសុំកូនជនបរទេសមកធ្វើជាកូនសុំរបស់ខ្លួនបាន។ ដោយយើងឃើញមានថា កម្ពុជា ធ្លាប់បានចុះហត្ថលេខា ជា**ភាគីនៃ អនុសញ្ញា ក្រុងឡាអេ ស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនិងការសុំកូនអន្តរប្រទេស** និង **បានបង្កើត ច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃ អនុសញ្ញា ទីក្រុងឡាអេ ស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទង និងសុំកូនអន្តរប្រទេស** ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ខែវិច្ឆិកា ឆ្នាំ២០០៦។

**លក្ខខណ្ឌក្នុងការទទួលសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ**

តាមខ្លឹមសារនៃ មាត្រា ១០ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ បានអនុញ្ញាតិអោយពលរដ្ឋខ្មែរធ្វើ ការសុំកូនបរទេសមកធ្វើជា កូនរបស់ខ្លួនដែលមាន ឋានៈ និងត្រូវទទួលសិទ្ធិ និង ករណីកិច្ចដូចនឹងកូនបង្កើតក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម ហើយកូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។ ការសុំកូននេះ ត្រូវស្តែងឡើងតាមរយៈលក្ខខណ្ឌមួយចំនួននៃរដ្ឋរបស់កូនសុំ និងលក្ខខណ្ឌមួយចំនួនទៀតនៃរដ្ឋរបស់ឪពុកម្តាយចិញ្ចឹមផងដែរ។ ដោយការសុំកូននេះត្រូវបានធ្វើឡើងតាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសទាំងពីរ ( ប្រទេសរបស់កូនសុំ និងប្រទេសរបស់ឪពុកម្តាយចិញ្ចឹម ) ដែលការសុំកូននេះអាចធ្វើឡើងបានចំពោះតែរដ្ឋដែលជាភាគីនៃ **អនុសញ្ញា ក្រុងឡាអេ ស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនិងការសុំកូនអន្តរប្រទេស** តែប៉ុណ្ណោះ។

---

[57] មាត្រា ២ នៃច្បាប់ស្តីពីសញ្ជាតិថ្មី ចំនុច ២ ( ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ )

[58] មាត្រា ១០ នៃច្បាប់ស្តីពីសញ្ជាតិថ្មី

**យោងតាមអនុសញ្ញា ក្រុងឡាអេ ស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទង និងការសុំកូនអន្តរប្រទេស មាត្រា ៤ និងមាត្រា ៥ បានចែងថា ការសុំកូនដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការគោរពលក្ខខណ្ឌនៃរដ្ឋជាភាគីទាំងពីរ (រដ្ឋនៃកូនសុំ នឹង រដ្ឋនៃអ្នកសុំ)។** ដោយឱ្យរដ្ឋជាភាគីត្រូវចាត់តាំងអាជ្ញាធរកណ្តាល ដើម្បីបំពេញករណីយកិច្ចដែល អនុសញ្ញាបានកំណត់។[59] រដ្ឋសហព័ន្ធ ដែលជារដ្ឋមានប្រព័ន្ធច្បាប់លើសពីមួយ ឬរដ្ឋដែលមានដែនដីស្វ័យតត្រូវមានសេរីភាពតែងតាំងអាជ្ញាធរកណ្តាលពិសេសលើសពីមួយ និងបញ្ជាក់សមត្ថកិច្ចដែនដី ឬសមត្ថកិច្ចមុខងារទាំងនោះ ហើយក្នុងករណីដែលរដ្ឋមួយបានតែងតាំអាជ្ញាធរកណ្តាលើសពីមួយរដ្ឋនោះត្រូវចង្អុលប្រាប់ថា អាជ្ញាធរកណ្តាលណាមួយអាចបញ្ជូនពិតមាន ទៅអាជ្ញាធរកណ្តាលសមស្របក្នុងរដ្ឋ។[60] មានន័យថា អាជ្ញាធរកណ្តាលទាំងអស់ត្រូវបានតែងតាំងដោយ ប្រទេសសាមីរបស់ខ្លួនទៅតាមបរិបទច្បាប់នៃប្រទេសនីមួយៗដែលជាភាគីនៃអនុសញ្ញានេះ។ អាជ្ញាធរកណ្តាលទាំងឡាយត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ហើយត្រូវឡើកស្ទួយសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋរបស់ខ្លួនដើម្បីឱ្យការពារកុមារ និងដើម្បីសម្រេចគោលបំណងនៃអនុសញ្ញា។[61] អាជ្ញាធរកណ្តាលទាំងឡាយត្រូវចាត់វិធានការសមស្រប និងដោយផ្ទាល់ដើម្បីផ្តល់ពត៌មានអំពីច្បាប់នៃរដ្ឋទាំងឡាយរបស់ខ្លួនដែលពាក់ព័ន្ធនឹងការសុំកូន និងពត៌មានទូទៅដទៃទៀតដូចជាស្ថិតិ និងទម្រង់បទដ្ឋាន និងអាជ្ញាធរកណ្តាលនីមួយៗត្រូវដឹងទៅវិញទៅមកអំពីប្រតិបត្តិការនៃអនុសញ្ញា ហើយបើអាចធ្វើទៅបានកំចាត់ចោលឧបសគ្គទាំងឡាយនៃការអនុវត្តន៍នៃអនុសញ្ញា។[62] អាជ្ញាធរកណ្តាលទាំងឡាយដោយផ្ទាល់ក្តី ឬតាមរយៈអាជ្ញាធរសាធារណៈក្តីត្រូវចាត់វិធានការទាំងអស់ដែលសមស្របដើម្បីទប់ស្កាត់ការកេងចំណេញមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ ឬការកេងយកចំណេញដទៃទៀតដែលទាក់ទងនឹងការសុំកូន និងដើម្បីទប់ស្កាត់ការអនុវត្តន៍ទាំងអស់ដែលផ្ទុយពីអនុសញ្ញា។[63]

**៣ ការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍**

ក្នុងការយល់ដឹងឱ្យកាន់តែច្បាស់អំពីការទទួលបានសញ្ជាតិខ្មែរតាមចំណងអាពាហ៍ពិពាហ៍ជាដំបូង យើងត្រូវស្វែរយល់ថា តើអ្វីទៅជាអាពាហ៍ពិពាហ៍? ជាមុនសិនះ

[59] យោងតាមមាត្រា ៦ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[60] យោងតាមមាត្រា ៦ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[61] យោងតាមចំនុច ១ មាត្រា ៧ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[62] យោងតាមចំនុច ២ មាត្រា ៧ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[63] យោងតាមមាត្រា ៨ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

**អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយ ដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចនឹងរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ ដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍[64]។**

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ស្តីពី អាពាហ៍ពិពាហ៍។ ការរៀបអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងពីរ។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ហើយគ្មានជនណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀបអាពាហ៍ពិពាហ៍ ឬរាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ[65]។

ដោយផ្អែកតាមនិយមន័យរបស់អាពាហ៍ពិពាហ៍ចំពោះបុគ្គលទាំងឡាយណាដែលចង់បានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍នោះ មានន័យថាការផ្តល់សញ្ជាតិខ្មែរ តាមរយៈអាពាហ៍ពិពាហ៍ឲ្យទៅបុរស ឬស្ត្រីបរទេស លុះត្រាតែបុរស ឬស្ត្រីបរទេសនោះ បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ និងបានរួមរស់ជាមួយសហព័ន្ធរបស់ខ្លួន ( បុរស ឬស្ត្រីជាពលរដ្ឋខ្មែរ ) រហូតដល់ថ្ងៃសុំសញ្ជាតិខ្មែរ។

ការទទួលបានសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍នេះស្តែងតាមរូបភាពដូចជា ៖

- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលកំពុងរស់នៅស្របច្បាប់ឯបរទេស។

រាល់អាពាហ៍ពិពាហ៍ត្រូវតែគោរពទៅតាមលក្ខខណ្ឌគោលនៃព្រះរាជាណាចក្រកម្ពុជាដូចជា៖

- បុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង
- នារីត្រូវតែអាយុចាប់ពី ១៨ឆ្នាំឡើង
- ក្នុងករណីពិសេស បុរសដែលមានអាយុមិនគ្រប់ ២០ឆ្នាំ និងនារីមានអាយុមិនគ្រប់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ព្រមទាំងមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល។
- ក្នុងករណីសហព័ន្ធណាមួយបាត់ខ្លួនលើសពីមួយឆ្នាំ ដោយគ្មានអ្នកណាដឹងថាស្លាប់ ឬរស់ សហព័ន្ធម្នាក់ទៀត អាចរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន។ ករណីនេះគ្មានជនណាអាចប្តឹងបដិសេធអាពាហ៍ពិពាហ៍ថ្មីនេះបានឡើយ ទោះបីជាសហព័ន្ធដែលបាត់ខ្លួនត្រឡប់មកវិញក៏ដោយ។

[64] យោងតាមមាត្រា ៣ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩

[65] យោងតាមមាត្រា ១៤ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩

ការរៀបអាពាហ៍ពិពាហ៍ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមិនអាចប្រព្រឹត្តទៅបានក្នុងលក្ខខណ្ឌដូចជា៖

- បុគ្គលដែលមានភេទដូចគ្នា
- បុគ្គលដែលគ្មានពលានុភាពនៃលឹង្គ
- បុគ្គលដែលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគដែលមិនទាន់បានព្យាបាលជាដាច់
- ជនវិកលចរិក មិនដឹងខុសត្រូវ
- បុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ
- បុគ្គលដែលជាប់ចំណងសាច់ញាតិលោហិត(ញាតិដែលមានឈាមជាមួយគ្នា) ឬញាតិពន្ធ ឬឥតខាន់ស្លា ឬ សាច់ញាតិចិញ្ចឹម។

**ឧទាហរណ៍៖**

- ឪពុកម្តាយ និងកូន ( ថ្នាក់ទី១ ) បងប្អូនបង្កើត ( ថ្នាក់ទី២ ) មា មីង និងក្មួយ ( ថ្នាក់ទី៣ ) មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។
- បងប្អូនថ្លៃ( សាខាញាតិពន្ធថ្នាក់ទី២ ) មាមីងនិងក្មួយប្រសារ ( សាខាញាតិពន្ធថ្នាក់ទី៣) អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានផ្លូវច្បាប់ ប្រសិនបើសហព័ន្ធណាមួយស្លាប់។

រាល់ទម្រង់រូបភាពដែលមានលក្ខណៈជាការរៀបអាពាហ៍ពិពាហ៍ គឺត្រូវតែមានការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយបុរស ឬស្ត្រី ជាជនជាតិបរទេស ឬខ្មែរ ត្រូវតែគោរពទៅតាមច្បាប់កំណត់។

**លក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍**

ដោយយោងទៅតាមមាត្រា ១១ នៃច្បាប់ ស្តីពី សញ្ជាតិ ២០១៨ “**ស្ត្រី ឬបុរស ដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេល ៣ឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចណាស់រយៈពេល ១២ ( ដប់ពីរ ) ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានអនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន។**” ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចដែលមានចែងក្នុង មាត្រា ១២ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ ដូចជា៖ ត្រូវមានគំនិតមារយាទ និងសីលធម៌ល្អ។ ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍។ ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ។ មានបញ្ញា និងការសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនៃឱ្យមានបន្ទុកដល់ជាតិ។

ជនបរទេសដែលសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍អាចសុំប្តូរឈ្មោះជាខ្មែរបាន ក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំទាមទារសញ្ជាតិខ្មែររបស់ខ្លួន។

**៤ ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម**

ក្រៅពីការទទួលបានសញ្ជាតិខ្មែរពីកំណើត ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ និងការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ជនបរទេសក៏អាចទទួលបានសញ្ជាតិខ្មែរតាមរយៈ**សញ្ជាតូបនីយកម្ម ( ការសុំចូលសញ្ជាតិ )**។ សញ្ជាតូបនីយកម្ម សំដៅដល់ការផ្តល់សញ្ជាតិខ្មែរតាមរយៈការស្នើរសុំរបស់ជនបរទេស ដោយផ្អែកតាមលក្ខខណ្ឌនៃការស្នាក់នៅការវិនិយោគ អំណោយជាសាច់ប្រាក់ និងគុណសម្បត្តិពិសេស ឬស្នាដៃពិសេស។[66] សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនេះអាចត្រូវបដិសេដចោលតាមអំណាចឆន្ទានុសិទ្ធិ។[67]

ម្យ៉ាងវិញទៀត តាមរយៈសញ្ជាតូបនីយកម្មនេះ ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន ដែលមានបំណងស្នើសុំចូលអាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារបាន។[68] ជនបរទេសនោះក៏អាចសុំប្តូរឈ្មោះជាខ្មែរផងដែរ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន។[69]

ការផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មដល់ជនបរទេសត្រូវសំរេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[70] ជនបរទេសដែលព្រះមហាក្រត្យបានប្រទានអោយចូលសញ្ជាតិខ្មែរត្រូវធ្វើសម្បតនៅចំពោះមុខតុលាការកំពូល។ ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរត្រូវប្រគល់ជូនសាមុីខ្លួន បន្ទាប់ពីធ្វើសម្បថរួច។[71]

ការទទួលសញ្ជាតិតាមសញ្ជាតូបនីយកម្ម អាចធ្វើបានតាមរយៈ ជនបរទេសដែលធ្វើការវិនិយោគត្រឹមត្រូវតាមច្បាប់ ពីស្ថាប័នមានសមត្ថកិច្ចហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១៩ មាត្រា ២០ និង មាត្រា ២១ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ ជនបរទេសដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិសម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៃព្រះរាជាណាចក្រកម្ពុជា និងជនបរទេសដែលមានគុណសម្បត្តិពិសេស ឬថ្វីដៃពិសេស និង ការស្នើសុំសញ្ជាតិជាចង្កោមគ្រួសារ។

[66] មាត្រា ៩ ចំនុច ៣ ច្បាប់ស្តីពីសញ្ជាតិ ២០១៨ នៃព្រះរាជាណាចក្រកម្ពុជា
[67] មាត្រា ១៨ ច្បាប់ស្តីពីសញ្ជាតិ ២០១៨ នៃព្រះរាជាណាចក្រកម្ពុជា
[68] មាត្រា ២៤ នៃច្បាប់ស្តីពីសញ្ជាតិ ២០១៨
[69] មាត្រា ២៥ នៃច្បាប់ស្តីពីសញ្ជាតិ ២០១៨
[70] មាត្រា ២៥ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់សញ្ជាតិ ២០១៨
[71] មាត្រា ២៦ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់សញ្ជាតិ ២០១៨

ការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរ ដោយសញ្ញាតូបនីយកម្មរបស់ជនបរទេសត្រូវបង់កម្រៃសេវា ដែលកម្រៃសេវានៃការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្មត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[72]

**លក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ញាតូបនីយកម្ម**

ជនបរទេសដែលអាចសុំចូលសញ្ជាតិខ្មែរតាមរយៈសញ្ញាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌក្នុងមាត្រា ១៩ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ ដូចជា៖

ត្រូវមានគំនិត មារយាទ និងសីលធម៌ល្អ។ ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន ៧ ( ប្រាំពីរ ) ឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលបណ្ណស្នាក់នៅ ដែលចេញអោយក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីច្បាប់អន្តោប្រវេសន៍ចំពោះជនបរទេសអន្តោប្រវេសន្ត។ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញអោយក្នុងក្របខ័ណ្ឌនៃច្បាប់ ស្តីពី អន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់ក្នុងមាត្រា២១ និង មាត្រា២២ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨។ ត្រូវចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងថាខ្លួនអាចរស់នៅសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់ និងប្រពៃណីដ៏ល្អរបស់ខ្មែរ។ មានបញ្ញា និងកាយសម្បទាដែលមិននាំអោយមានគ្រោះថ្នាក់ ឬនាំអោយមានបន្ទុកដល់ជាតិ។

ប៉ុន្តែក៏មានករណីលើកលែងមួយចំនួនដែលអាចជួយសំរួលដល់ជនបរទេសដែលចង់ចូលសញ្ជាតិជាពិសេសទាក់ទងទៅនឹងរយៈពេលនៃការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសំរាប់ ជនបរទេសអន្តោប្រវេសន៍ណាដែលកើតក្នុងព្រះរាណាចក្រកម្ពុជា រយៈពេលនៅជាប់ចំនួន ៧ ( ប្រាំពីរ ) ឆ្នាំ ត្រូវកាត់បន្ថយមកត្រឹម ៣ ( បី ) ឆ្នាំវិញ។[73]

**លក្ខខណ្ឌពិសេសក្នុងការទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ញាតូបនីយកម្មតាមមាត្រា ១៩ មាត្រា ២០ និងមាត្រា ២១**

យោងតាមមាត្រា ១៩ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ បានចែងត្រឹមតែលក្ខខណ្ឌទូទៅតែប៉ុណ្ណោះ។ រីឯលក្ខខណ្ឌក្នុងការចូលសញ្ជាតិខ្មែរតាមលក្ខខណ្ឌពិសេសមានចែងនៅក្នុងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ដែលជាអនុក្រឹត្យអមបន្ថែមលើច្បាប់ សញ្ជាតិថ្មីនេះ។ ជនបរទេសទាំងឡាយ អាចសុំទាមទារសញ្ជាតិតាមរយៈសញ្ញាតូបនីយកម្មបានដោយពុំចាំបាច់បំពេញតាមលក្ខខណ្ឌទូទៅទាំងស្រុងនោះទេ ប៉ុន្តែត្រូវបំពេញតាមលក្ខខណ្ឌពិសេសសំរាប់ជនបរទេសណាដែលបានទទួលការអនុញ្ញាតិអោយវិនិយោគត្រឹមត្រូវតាមច្បាប់ពីស្ថាប័នមានសមត្ថកិច្ច ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យ

[72] មាត្រា ២៤ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់សញ្ជាតិ ២០១៨

[73] មាត្រា ២០ ច្បាប់ស្តីពីសញ្ជាតិ ២០១៨ នៃព្រះរាជាណាចក្រកម្ពុជា

សុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្មបាន ក្នុងករណីជននោះបានបំពេញលក្ខខណ្ឌដូចមានចែង ក្នុងចំណុចទី១ ទី២ ទី៤ ទី៥ និងទី៦ នៃមាត្រា១៩ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល១២ ( ដប់ពីរ ) ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា។[74] ជនបរទេសដែលបានទទួលការអនុញ្ញាតិអោយវិនិយោគត្រឹមត្រូវតាមច្បាប់ ត្រូវចំណាយទុនវិនិយោគជាក់ស្តែងក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពី៤ ០០០ ០០០ ០០០៛ (បួនប៊ីលាន) រៀលឡើងទៅ និងធ្វើការវិនិយោគលើគម្រោង និងវិស័យអាទិភាពដូចដែលបានកំណត់ដោយអនុក្រឹត្យ និងបំពេញលក្ខខណ្ឌផ្សេងទៀតដូចជាកាតព្វកិច្ចសារពើពន្ធ និងផែនការវិនិយោគ។[75]

គម្រោង និងវិស័យអាទិភាពដែលវិនិយោគិនអាចស្នើសុំចូលសញ្ជាតិខ្មែរបានមានដូចជា៖

១. កសិកម្ម។

២. កសិ-ឧស្សាហកម្ម។

៣. សហគ្រាសផលិត និងកែច្នៃម្ហូបអាហារ។

៤. សហគ្រាសកម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក ផលិតផលទំនិញនាំចូល និងសហគ្រាសកែច្នៃសំណល់ Recycle ។

៥. សហគ្រាសកម្មន្តសាលដែលជាឧស្សាហកម្មអនុគមន៍ ឧស្សាហកម្មប្រតិគមន៍ និងផលិតកម្មទំនិញសម្រាប់វិស័យទេសចរណ៍ ។

៦. សហគ្រាសនវានុវត្តន៍ Innovation start-up ដែលស្ថិតក្នុងវិស័យឌីជីថល និងមានបច្ចេកវិទ្យាទំនើប។

៧. សហគ្រាសស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាផលិតកម្ម។

៨. សហគ្រាសដែលស្ថិតនៅក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសអភិវឌ្ឍតំបន់ SMEs។

៩. ឧស្សហកម្មកម្មន្តសាលថ្មីៗ ដែលមានចរិកជាការបើកច្រកចូលទីផ្សារ ផ្តល់តម្លៃបន្ថែមខ្ពស់ មានភាពច្នៃប្រឌិត និងមានការប្រកួតប្រជែងខ្ពស់ៗ ។

១០. ប្រភេទឧស្សាហកម្មបម្រើ អោយខ្សែច្រវាក់ផលិតកម្មតំបន់ និងមានចរិកយុត្តិសាស្ត្រសម្រាប់ពេល អនាគត ដូចជាឧស្សាហកម្មធុនធ្ងន់ និងឧស្សាហកម្មពាក់ព័ន្ធនឹងបច្ចេកវិទ្យាបៃតង។

១១. វិស័យធនាគារ និងស្ថាប័នហិរញ្ញប្បទានដល់ SMEs។

១២. ការវិនិយោគក្នុងវិស័យលំនៅដ្ឋានមានតម្លៃសមរម្យ ឬលំនៅដ្ឋានតាមតំបន់ដែលរាជរដ្ឋាភិបាលចាត់ទុកជាអាទិភាព។

[74] មាត្រា ២១ នៃច្បាប់ ស្តីពីសញ្ជាតិ ២០១៨ នៃព្រះរាជាណាចក្រកម្ពុជា

[75] មាត្រា ២៨ នៃអនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

ដូចគ្នានេះដែលចំពោះជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរបានដោយសញ្ជាតូបនីយកម្មបានតាម មាត្រា២២ នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលជននោះបានធ្វើ**អំណោយជាសាច់ប្រាក់ចំនួនចាប់ពី ១២ ០០០ ០០០ ០០០ (ដប់ពីរប៊ីលាន) រៀលឡើងទៅ**។ អំណោយជាសាច់ប្រាក់នោះត្រូវតែជាសាច់ប្រាក់ផ្ទាល់ខ្លួន ត្រូវមានប្រភពច្បាស់លាស់និង ស្របច្បាប់ ហើយអំណោយនោះត្រូវបង់ចូលជាថវិកាជាតិ តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។[76]

ក្រៅពីនេះ ជនបរទេសណាដែលបានបង្ហាញថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៦ នៃមាត្រា ១៩ នៃច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨នេះ។[77] សំរាប់ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជនដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារបាន។[78]

---

[76] មាត្រា ៣០ នៃអនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

[77] មាត្រា ២៣ នៃច្បាប់ ស្តីពីសញ្ជាតិ ២០១៨ នៃព្រះរាជាណាចក្រកម្ពុជា

[78] មាត្រា ២៤ នៃច្បាប់ ស្តីពីសញ្ជាតិ ២០១៨

## ជំពូកទី ២ ទម្រង់បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ និងច្បាប់សញ្ជាតិ

នៅក្នុងជំពូកទី ២ បែបបទ នីតិវិធី អានុភាព និងការបាត់បង់នៃសញ្ជាតិខ្មែរ ត្រូវបានចែកចេញជាពីរ ផ្នែក។ ដោយផ្នែកទី១ បង្ហាញពី ទម្រង់បទដ្ឋានគតិយុត្ត និងអានុភាពនៃការចូលសញ្ជាតិខ្មែរ (កថាខណ្ឌទី១ លិខិតបទដ្ឋានគតិយុត្តនៃការចូលសញ្ជាតិខ្មែរ កថាខណ្ឌទី២ អានុភាពនៃការចូលសញ្ជាតិខ្មែរ និងផ្នែកទី២ បង្ហាញពី ការបាត់បង់នៃសញ្ជាតិខ្មែរ និងទោសបញ្ញាតិ (កថាខណ្ឌទី ១ ៖ ការបាត់បង់នៃសញ្ជាតិខ្មែរ និងកថាខណ្ឌទី២ ៖ ទោសបញ្ញត្តិ)។

### ផ្នែកទី ១ ទម្រង់បទដ្ឋានគតិយុត្ត និងអានុភាពនៃការទទួលបានសញ្ជាតិខ្មែរ

#### កថាខណ្ឌទី ១ លិខិតបទដ្ឋានគតិយុត្តនៃការទទួលបានសញ្ជាតិខ្មែរ

#### ១ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរពីកំណើត

គ្រប់រូបវន្តបុគ្គលដែលកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែទៅសុំចុះបញ្ជីអត្រានុកូលដ្ឋាន។ វាជាកាតព្វកិច្ចរបស់ឪពុកម្ដាយជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ/សង្កាត់ដែលខ្លួនស្នាក់អចិន្ត្រៃយ៍ ដោយយោងតាមអនុក្រឹត្យចាស់លេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០។ នៅក្នុងអនុក្រឹត្យនោះផងដែរ ក៏បានបង្ហាញពីនីតិវិធីនៃការចុះសំបុត្រកំណើត ឬសំបុត្របញ្ជាត់កំណើត ទៅដល់ប្រជាពលរដ្ឋខ្មែរនូវសញ្ជាតិខ្មែរយ៉ាងពេញលេញ។ ក្នុងនោះផងដែរ បានបញ្ជាក់ពីនីតិវិធីនៃការចុះបញ្ជីសំបុត្រកំណើត ឬបញ្ជីបញ្ជាក់កំណើតដូចជា ៖

- បើមានទារកកើត ឪពុក ឬម្ដាយ ត្រូវតែមានកាតព្វកិច្ចទៅរាយការណ៍ ចុះសៀវភៅកំណើត នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ/សង្កាត់ នៃលំនៅអចិន្ត្រៃយ៍របស់ឪពុក ឬម្ដាយទារកមិនឱ្យហួស ៣០ថ្ងៃឡើយ ដោយត្រូវបញ្ជាក់ឱ្យច្បាស់ថា ឪពុក និងម្ដាយនៃទារកនោះ មានខាន់ស្លា ឬឥតខាន់ស្លា។[79] បើមានខាន់ស្លាត្រូវមានបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និងម្ដាយ ទារកនោះជាដាច់ខាត។ ប៉ុន្តែ ប្រសិនបើឪពុក ឬម្ដាយនោះមិនមានខាន់ស្លាត្រូវតែមានលិខិតបញ្ជាក់ពី មេភូមិ ឬសាក្សីផងដែរ។ ក្នុងករណី ឪពុកម្ដាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះដែលកើតត្រូវតែឱ្យទៅចុះបញ្ជីក្នុងសៀវភៅកំណើតឱ្យបានទាន់ពេលកំណត់ ដោយត្រូវយកភ្ជាប់ទៅជាមួយសំបុត្រអាពាហ៍ពិពាហ៍ឪពុក និងម្ដាយទារកនោះផងដែរ។[80] ចំពោះការដាក់នាមត្រកូលឱ្យទារកវិញអាចយកតាមណាក៏បានស្រេចតែក្រុមគ្រួសារជាអ្នកកំណត់យកតាំងពីដូនតាយូរលង់មក ឬអាចយកឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកក៏បាន ដែលឪពុកម្ដាយ ឬអាណាព្យាបាលជាអ្នកដាក់នាមអោយទារក។[81]

---

[79] យោងតាមមាត្រា ១៧ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[80] យោងតាមមាត្រា ១៧ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[81] យោងតាមមាត្រា ១៨ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

កូនដែលរើសបានត្រូវប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋាននៃទីកន្លែងដែលរើសបានទារកដើម្បីធ្វើកំណត់ហេតុ និងចុះបញ្ជីកំណើតនិងដាក់ឈ្មោះព្រមទាំពិគ្រោះជាមួយមន្ត្រីសុខាភិបាលដើម្បីដាក់ថ្ងៃខែកំណើត។ បើមានគេសុំ ត្រូវដាក់នាមត្រកូលតាមអ្នកសុំ។ បើគ្មានអ្នកសុំត្រូវបញ្ជូនអោយមជ្ឈមណ្ឌលទារក ឬកុមារកំព្រាដែលនៅជិត ដែលមានភ្ជាប់នូវសំបុត្រកំណើត និងកំណត់ហេតុស្តីពីការប្រគល់ទារក។[82]

ទារកដែលឪពុក ឬម្តាយបោះបង់ចោល ឬមិនទទួលស្គាល់ ដែលតុលាការបានចេញសាលក្រមបញ្ជាក់ថាពិតជាមានឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ គឺទារក ឬកុមារនោះ ដែលគេបានរើសហើយកំពុងចិញ្ចឹមបីបាច់ថែរក្សានៅក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ឬអង្គការ ឬមណ្ឌលក្រៅរដ្ឋាភិបាលក៏ដោយ ដែលពុំទាន់មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ឬប្រធានអង្គការ មណ្ឌល ត្រូវធ្វើសេចក្តីរាយការណ៍ និងនាំទារក ឬកុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ/សង្កាត់ ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីឱ្យមន្ត្រីអត្រានុកូលដ្ឋានផ្តល់នូវសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ។[83]

ទារកដែលមានម្តាយជាទណ្ឌិតត្រូវសម្រាលកូននៅទីនោះ ត្រូវតែចុះបញ្ជីសំបុត្រកំណើត ឬលិខិតបញ្ជាក់កំណើតរបស់ទារកដោយយកតាមលំនៅឋានម្តាយ ឬឪពុករបស់ទារកនោះ។[84]

ទារកដែលកើតពីឪពុក ឬម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវតាមច្បាប់ក៏ត្រូវចុះបញ្ជីអត្រានុកូលដ្ឋានផងដែរ ដោយឪពុក ឬម្តាយដែលពុំមានចំណងអាពាហ៍ពិពាហ៍នោះ ត្រូវតែឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន ដោយមន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកថា ឪពុកនិងម្តាយរបស់ទារកនោះមែន។ ចំពោះករណីដែលមានតែម្តាយ ឬឪពុកតែម្នាក់គត់ដែលទទួលស្គាល់ ទារកនោះត្រូវចាត់ទុកជាកូនរបស់ឪពុក ឬម្តាយតែម្នាក់គត់។ ប៉ុន្តែប្រសិនបើ ម្តាយ ឬឪពុកនោះ បានចុះសំបុត្រអាពាហ៍ពិពាហ៍តាមក្រោម ទារកនោះនឹងក្លាយទៅជាកូនមានខាន់ស្លាវិញ។[85]

នៅក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍នូវសំបុត្រកំណើតរបស់ទារក ដោយប្រគល់ច្បាប់ដើម ០១សន្លឹកទុកជាការសម្គាល់ របស់រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរពេញលក្ខណៈ។

ប៉ុន្តែប្រសិនបើ ទារកកើតហើយ ទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ពុំបានរាយការណ៍ចុះសៀវភៅកំណើតរបស់ទារកទៅដល់មន្ត្រីអត្រានុកូលដ្ឋាន ទារកនោះក៏មិនអាចបាត់បង់សញ្ជាតិដែរ គឺម្តាយ ឬឪពុក

---

[82]យោងតាមមាត្រា ១៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[83] យោងតាមមាត្រា ២០ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[84] យោងតាមមាត្រា ២១ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

[85] យោងតាមមាត្រា ២៣ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

ឬអាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត/ក្រុង សាមី ដើម្បីឱ្យតុលាការចេញសាលក្រមស្ដាពរចំពោះការផ្ដល់សញ្ញាតិខ្មែរតាមរយៈផ្លូវច្បាប់។ មិនតែប៉ុណ្ណោះ ម្ដាយ ឬឪពុក ឬអាណាព្យាបាលត្រូវយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ/សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះក្នុងសៀវភៅកំណើត។[86]

ចំណែកឯទារកដែលមានឪពុក ឬម្ដាយមានសញ្ញាតិខ្មែរ ឬពលរដ្ឋខ្មែរ ដែលរស់នៅឯបរទេសស្របច្បាប់ក៏ត្រូវបានចុះបញ្ជីកំណើតនៅឃុំ/សង្កាត់ ដែលខ្លួនរស់នៅតាមសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត របស់ឪពុក ឬម្ដាយ ដែលមានសញ្ញាតិខ្មែរនោះ ស្របទៅតាមច្បាប់សញ្ញាតិខ្មែរឆ្នាំ២០១៨នេះផងដែរ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រកំណើតថ្មីឱ្យយកទៅប្រើប្រាស់។ ឪពុក ឬម្ដាយរបស់ទារកនោះ ត្រូវតែរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំការនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយក សំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន។[87]

ចំពោះជនអន្តោប្រវេសន៍ និងជនបរទេសដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឪពុកម្ដាយទារកនោះអាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ/សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុង ឬស្ថានកុលស៊ុងនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ បើចុះសៀវភៅកំណើតនៅសាលាឃុំ/សាលាសង្កាត់ នាមត្រកូល និងនាមផ្ទាល់ខ្លួន និងនាមនៃឪពុកម្ដាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង។ ចំពោះ សញ្ញាតិនៃកូននោះ ត្រូវអនុវត្តតាម ច្បាប់ ស្ដីពី សញ្ញាតិ នៃព្រះរាជាណាចក្រកម្ពុជា។

**២ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ញាតិខ្មែរដោយការសុំកូនពេញលេញ**

ដូចដែលបានបកស្រាយខាងលើរួចមកហើយ ( **២ លក្ខខណ្ឌក្នុងការទទួលសញ្ញាតិខ្មែរដោយការសុំកូនពេញលេញ** ) ចំពោះបែបបទ និងនីតិវិធីនៃការទទួលបានសញ្ញាតិខ្មែរតាមរយៈសុំកូនពេញលេញត្រូវបានចែងក្នុងច្បាប់ស្ដីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្ដីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស។

ដូចនេះដើម្បីអាចធ្វើការសុំកូនអន្តរប្រទេសនេះបាន សហព័ន្ធជាពលរដ្ឋខ្មែរត្រូវដាក់ពាក្យស្នើសុំទៅអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជាពេញចិត្តនូវលក្ខណៈសម្បត្តិ និងយល់ថាអ្នកស្នើសុំនោះសមស្របអាចយកកុមារមក ចិញ្ចឹមបាន អាជ្ញាធរកណ្ដាលនោះ នឹងរៀបចំរបាយការណ៍មួយដែលតម្រូវអោយអ្នកសុំធ្វើការបំពេញ ( អត្តសញ្ញាណលក្ខ

[86] យោងតាមមាត្រា ២៥ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្ដីពីអត្រានុកូលដ្ឋានឆ្នាំ២០០០
[87] យោងតាមមាត្រា ២៦ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្ដីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

ណៈសម្បត្តិនៃអ្នកសុំ ប្រវត្តិគ្រួសារ ប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិផ្នែកពេទ្យ បរិយាកាសសង្គម ហេតុផលនៃការសុំកុមារ និងសមត្ថភាពនៃអ្នកសុំ ព្រមទាំងចរិកលក្ខណៈនៃកុមារដែលសុំ) ហើយធ្វើការផ្ញើរទៅរដ្ឋរបស់របស់កូនសុំ។[88] នៅពេលដែលអាជ្ញាធរកណ្តាលនៃរដ្ឋរបស់កូនសុំបានទទួលនូវរបាយការណ៍អាជ្ញាធរកណ្តាលនៃរដ្ឋនោះនឹងធ្វើការរៀបចំឯកសារដែលទាក់ទងនិងកុមារ ( ប្រវត្តិ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិផ្នែកពេទ្យរបស់កុមារ រួមទាំងប្រវត្តិផ្នែកពេទ្យនៃក្រុមគ្រួសារកុមារ និងសេចក្តីត្រូវការពិសេសរបស់កុមារ ) និងធ្វើការពិចារណាដល់ការចិញ្ចឹមបីបាច់កុមារ និងប្រវត្តិជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារ និងធានាដល់ការយល់ព្រម និងសំរេចដល់ឧត្តមប្រយោជន៍នៃកុមារដែលសំអាងជាពិសេសដោយរបាយការណ៍ទាក់ទងនឹងកុមារ និងអនាគត់ឪពុកម្តាយចិញ្ចឹម។[89] ក្រោយមកទៀតអាជ្ញាធរកណ្តាលនៃរដ្ឋរបស់កូនសុំត្រូវធ្វើការបញ្ជូនរបាយការណ៍របស់ខ្លួនទៅអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ដែលទាមទារភស្តុតាងដែលបញ្ជាក់អំពីការយល់ព្រមជាចំបាច់ និងហេតុផលនៃការសំរេចរបស់ខ្លួនស្តីពីការឱ្យកូនសុំនោះដោយយកចិត្តទុកដាក់មិនបញ្ចេញឱ្យដឹងអត្តសញ្ញាណនៃម្តាយ និងឪពុកកុមារ ប្រសិនបើអត្តសញ្ញាណនេញមិនអាចបញ្ចេញអោយបាននៃរដ្ឋរបស់កូនសុំ។[90] សេចក្តីសំរេចណាមួយដែលរដ្ឋរបស់កូនសុំ ដែលសំរេចថាកុមារគួរតែបានប្រគល់អោយអនាគតឪពុកម្តាយចិញ្ចឹមអាចធ្វើទៅបានលុះណាតែ មានការធានាពីអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាថាអនាគតឪពុកម្តាយចិញ្ចឹមយល់ព្រម។ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាយល់ព្រមលើសេចក្តីសម្រេចក្នុងករណីច្បាប់ និងអាជ្ញាធរកណ្តាលនៃប្រទេសទាំងពីរយល់ព្រម និងដើម្បីពិនិត្យអោយឃើញថាអនាគតឪពុកម្តាយចិញ្ចឹមមានលក្ខណៈសម្បត្តិ និងសមស្របអាចយកកុមារទៅចិញ្ចឹមបាន ហើយកុមារនោះត្រូវបាន ឬនឹងត្រូវអនុញ្ញាតឱ្យចូល និងរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

ការផ្ទេរកុមារអាចអនុវត្តន៍ទៅបាន លុះត្រាតែលក្ខខណ្ឌខាងលើត្រូវបានបំពេញ ដែលនីតិវិធីនៃការផ្ទេរកុមារត្រូវធានាដល់សន្តិសុខ សុវត្ថិភាព និងមានភាពសមស្របដល់កុមារ ហើយបើមានករណីចាំបាច់ត្រូវមានការរួមដំណើរដោយអនាគតឪពុកម្តាយចិញ្ចឹម។ អាជ្ញាធរកណ្តាលត្រូវជូនពត៌មានគ្នាទៅវិញទៅមកជានិច្ចអំពីដំណើរការសុំកូន និង វិធានការដើម្បីធ្វើអោយការសុំកូននេះចប់សព្វគ្រប់។ ការសុំកូននឹងត្រូវបានសំរេចនៅពេលដែលកុមារបានមកដល់ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

---

[88] យោងតាមមាត្រា ១៥ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[89] យោងតាមចំនុច ១ មាត្រា ១៦ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

[90] យោងតាមចំនុច ២ មាត្រា ១៦ នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស

### ៣ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍

បែបបទ និងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ ត្រូវបានធ្វើឡើងជា ពីរ ដំណាក់កាល គឺ ៖

**មុនពេលរៀបអាពាហ៍ពិពាហ៍៖** ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមអនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។[91] ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងារជើសគូរស្រករឈ្មួញ កណ្តាល ឬក្រុមហ៊ុនអាជីវកម្ម។[92] ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយបោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។[93] ជនបរទេសដែលមាន បំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម ៖ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស និងត្រូវមាននីត្យានុកូលកម្ម លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស លិខិតបញ្ជាក់អំពីមុខរបរពិត ប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស សេចក្តីចម្លងសំបុត្រកំណើត ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់សាមីខ្លួន ត្រូវមានការបញ្ជាក់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមី និងត្រូវបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយត្រូវ

---

[91] យោងតាមមាត្រា ៦ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[92] យោងតាមមាត្រា ៣ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[93] យោងតាមមាត្រា ៤ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

មានបញ្ជាក់ពីនីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស[94] ប្រចាំព្រះរាជាណាចក្រកម្ពុជាដោយយោងតាមមាត្រា ៦ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស[95]ហើយត្រូវគោរពទៅតាមមាត្រា ៧ ដល់១២ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទនិងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។[96]

ចំពោះការចុះអត្រានុកូលដ្ឋាននៅតាមឃុំ/សង្កាត់វិញ ត្រូវគោរពទៅតាមអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ ជំពូកទី៥ ពីមាត្រា២៨ ដល់ ៣៤ នៃច្បាប់នេះ។[97]

**ក្រោយពេលរៀបអាពាហ៍ពិពាហ៍៖** យោងតាមអនុក្រឹត្យលេខ ១១២ អនក្រ.បក ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨ ដែលបានកំណត់ពីនីតិវិធីនៃការស្នើសុំសញ្ជាតិរបស់ជនបរទេស ដែលបានរៀបអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់កំណត់ជាមួយពលរដ្ឋខ្មែរអាចទាមទារសញ្ជាតិខ្មែរបានដោយត្រូវដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ហើយជនបរទេសនោះត្រូវតែមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដាក់ពាក្យស្នើសុំដែលត្រូវភ្ជាប់មកជាមួយដូចខាងក្រោម ៖ពាក្យទាមទារសញ្ជាតិខ្មែរចំនួន ០២ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ០២ច្បាប់ ដោយមានបិទរូបថតទំហំ ៤ស.ម គុណ ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក នឹងគ្មានពាក់វ៉ែនតាទំហំ ៤ស.ម គុណ ៦ស.ម ចំនួន ១០សន្លឹក សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន ០២ច្បាប់ លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ/ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ០២ច្បាប់ ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេល ១២ខែពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ០២ច្បាប់ ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ០២ច្បាប់ លិខិតបញ្ជាក់គំនិតមារយាទ និងសីលធម៌ចេញដោយមេឃុំ/ចៅសង្កាត់ នៃទីលំនៅរបស់សាមីខ្លួន ចំនួន ០២ច្បាប់ លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ចំនួន ០១ច្បាប់ លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០១ច្បាប់ លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០២

[94] យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[95] យោងតាមមាត្រា  នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[96] យោងតាមមាត្រា ៧ ដល់១២ នៃអនុក្រឹត្យលេខ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[97] យោងតាមមាត្រា ២៨ ដល់៣៤ នៃអនុក្រឹត្យលេខ១០៣ អនក្របកស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

ច្បាប់។[98] បន្ទាប់ពីបានបំពេញសំណើរនេះចប់សព្វគ្រប់អស់ហើយមន្ត្រីដែលមានសមត្ថកិច្ចនឹងធ្វើការកោះអញ្ជើញអ្នកដែលដាក់ពាក្យសុំសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មមកប្រឡង ដែលរៀបចំឡើងដោយគណៈកម្មការវាយតម្លៃរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ ការប្រឡងត្រូវធ្វើឡើងដោយការសម្ភាសន៍ ដើម្បីត្រួត ពិនិត្យលក្ខណៈសម្បត្តិ កាយសម្បទា កិរិយាមារយាទ បញ្ញាស្មារតី ការនិយាយស្តាប់ភាសាខ្មែរការចេះអាន សរសេរអក្សរខ្មែរ និងការយល់ដឹងនូវប្រវត្តិសាស្ត្រខ្មែរខ្លះៗ និងការពិនិត្យលើភស្តុតាងដែលបានបញ្ជាក់ថា សាមីខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់ល្អរបស់ខ្មែរ។ ក្នុងករណីចាំបាច់ គណៈកម្មការវាយតម្លៃអាចចាត់មន្ត្រីរបស់ខ្លួនអោយចុះអង្កេតពីស្ថានភាពនៃជីវភាពរស់នៅរបស់អ្នកដាក់ពាក្យសុំ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទទាមទារសញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណី អ្នកស្នើសុំមិនបានបំពេញ ត្រឹមត្រូវតាមលក្ខខណ្ឌដែលបាន កំណត់ក្នុង ច្បាប់ ស្តីពី សញ្ជាតិ ពីនីតិវិធី និងបែបបទដែលមានចែងក្នុងច្បាប់ទេ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ នៃថ្ងៃធ្វើការ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ និងបន្តនីតិវិធីលើការទាមទារសញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។[99] រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជនបរទេស ត្រូវតែមានការផ្តល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។[100] ទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ [101]
ការដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍របស់ជនបរទេសត្រូវបង់តម្លៃសេវាតាមការកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[102]

ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិខ្មែរដល់ជនបរទេសត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើររបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[103] ជនបរទេសដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរឱ្យ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។ ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរត្រូវប្រគល់ជូនសាមីខ្លួន បន្ទាប់ពីបានធ្វើសម្បថរួច។[104]

[98] យោងតាមមាត្រា ៥ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[99] យោងតាមមាត្រា ៧ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[100] យោងតាមមាត្រា ៨ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[101] យោងតាមមាត្រា ៩ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[102] យោងតាមមាត្រា ១០ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[103] យោងតាមមាត្រា ១១ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨
[104] យោងតាមមាត្រា ១២ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

**៤ បែបបទ និងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម**

សំរាប់ជនបរទេសដែលមានបំណងចង់ធ្វើការស្នើសុំសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវតែអនុវត្តន៍តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ អនុក្រឹត្យលេខ១១២អនក្រ.បក ស្តីពីការអនុវត្តច្បាប់សញ្ជាតិឆ្នាំ២០១៨ និងប្រកាស ស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និង នីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេដលើការសុំទាមទារសញ្ជាតិខ្មែរនេះ។ [105]

ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១ នៃច្បាប់ស្តីពីសញ្ជាតិត្រូវដាក់ពាក់សុំ និងបំពេញបែបបទដូចខាងក្រោមៈ ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ) ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន ២(ពីរ) ច្បាប់ ដោយមានបិទរូបថត ៤ស.ម គុណ ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ ៤ស.ម គុណ ៦ស.ម ចំនួន ១០( ដប់) សន្លឹក ច្បាប់ថតចម្លងបណ្ណស្នាក់នៅ ចេញដោយសមត្ថកិច្ចអន្តោប្រវេសន៍ចំនួន ២(ពីរ) ច្បាប់ បណ្ណការងារ ឬឯកសាបញ្ជាក់មុខរបរចំពោះជនបរទេសអន្តោប្រវេសន៍ដែលបានកំណត់ក្នុងចំណុចទី៣ មាត្រា១៩ និង មាត្រា២០ នៃច្បាប់ស្តីពីសញ្ជាតិចំនួន ០២(ពីរ) ច្បាប់ ឬឯកសារ ពាក់ព័ន្ធនឹងការវិនិយោគចំពោះជនបរទេស ដែលបានកំណត់នៅក្នុងចំណុច ៤ មាត្រា១៩ និងមាត្រា២១ នៃច្បាប់សញ្ជាតិ ចំនួន ០២ (ពីរ) ច្បាប់ លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ/ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន ២ (ពីរ)ច្បាប់ សេចក្តីចម្លងសំបុត្រកំណើត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ជនបរទេសចំនួន ២ (ពីរ) ច្បាប់ជាភាសាខ្មែរ ឬអង់គ្លេសដែលមានការបញ្ជាក់នីត្យានុកូលភាពពីប្រទេសសាមី និងឯកសារបញ្ជាក់ការស្នាក់នៅជាប់ ឬពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា ដូចបានកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១ នៃច្បាប់ស្តីពីសញ្ជាតិចំនួន ២(ពីរ)ច្បាប់ ច្បាប់ថតចម្លង លិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ២ (ពីរ) ច្បាប់ លិខិតបញ្ជាក់គំនិតមាយាទចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២(ពីរ) ច្បាប់ លិខិតថ្កោលទោសមានសុពលភាពត្រឹមថ្ងៃដាក់ពាក្យចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីចំនួន ០១ (មួយ) ច្បាប់ ដែលត្រូវបកប្រែជា ភាសាខ្មែរ ឬអង់គ្លេសដែលមានបញ្ជាក់នីត្យានុកូលភាពពីប្រទេសសាមី លិខិតថ្កោលទោសមានសុពលភាពត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០១ (មួយ) ច្បាប់ លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃ មន្ទីពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០២

[105] យោងតាមមាត្រា ២ នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

(ពីរ) ច្បាប់[106] លិខិតបញ្ជាក់អោយវិនិយោគដោយស្ថាប័នមានសមត្ថកិច្ច[107] លក្ខន្តិកៈក្រុមហ៊ុនដែលបានកំណត់ទុនវិនិយោគផ្ទាល់របស់អ្នកដាក់ពាក្យសុំត្រូវមានទំហំទឹកប្រាក់ចាប់ពី ៤,០០០,០០០,០០០ (បួនប៊ីលាន) រៀលឡើងទៅ[108] ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន[109] និងលិខិតបញ្ជាក់ពីធនាគារនូវចំនួនទឹកប្រាក់តម្កល់របស់អ្នកដាក់ពាក្យសុំ[110]។

ជនបរទេសដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌អាចសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម នឹងត្រូវបំពេញបែបបទដូចជា ៖ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២ (ពីរ) ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន ២(ពីរ) ច្បាប់ ដោយមានបិទរូបថត ៤ស.ម គុណ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ ៤ស.ម គុណ ៦ស.ម ចំនួន១០( ដប់) សន្លឹក លិខិតបញ្ជាក់អំពីសាច់ប្រាក់ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ (មួយ) ច្បាប់  សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាម៉ីខ្លួនជនបរទេសចំនួន ០២ (ពីរ) ច្បាប់ ដែលមាននីត្យានុកូលភាពពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាម៉ី និងត្រូវបកប្រែជាភាសាខ្មែរ ឬអង់គ្លេស[111] ឯកសារបញ្ជាក់ការ ស្នាក់នៅជាប់ ឬពេញលេញក្នុង  ព្រះរាជាណាចក្រកម្ពុជាដូចបានកំណត់ក្នុងមាត្រា២២ នៃច្បាប់ស្តីពីសញ្ញាតិ ចំនួន ០២ (ពីរ) ច្បាប់ ច្បាប់ថតចម្លង លិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ០២ (ពីរ) ច្បាប់ លិខិតបញ្ជាក់គំនិតមាយាទចេញដោយមេឃុំ/ចៅសង្កាត់នៃទីលំនៅរបស់សាម៉ីខ្លួនចំនួន ០២(ពីរ) ច្បាប់ លិខិតថ្កោលទោសមានសុពលភាពត្រឹមថ្ងៃដាក់ពាក្យចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាម៉ីចំនួន ០១ (មួយ) ច្បាប់ ដែលមាននីត្យានុកូលភាពពីស្ថាប័នមានសមត្ថកិច្ចនៃ

---

106 យោងតាមមាត្រា ១៧  នៃអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

107 យោងតាមចំនុច ៣ ប្រការ១៤ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូឡសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

108 យោងតាមចំនុច ៤ ប្រការ១៤ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូឡសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

109 យោងតាមចំនុច ៥ ប្រការ១៤ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូឡសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

110 យោងតាមចំនុច ៦ ប្រការ១៤ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូឡសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

111 យោងតាមចំនុច ១ ប្រការ១៤ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូឡសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

ប្រទេសសាមី៉ និងត្រូវបកប្រែជាភាសាខ្មែរ ឬអង់គ្លេស[112] លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន ០២ (ពីរ) ច្បាប់[113] ចំពោះឯកសារដែលពាក់ព័ន្ធនិងគុណសម្បត្តិពិសេស ឬថ្វីដៃពិសេសដែលបានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីសញ្ជាតិត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសពីរាជរដ្ឋាភិបាល[114]

ក្រៅពីការសុំចូលសញ្ជាតិដោយការវិនិយោគ និងការធ្វើអំណោយមនុស្សធម៌ជនបរទេសដែលបានបង្ហាញភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន និងត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃដូចជា ៖ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ) ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ) ច្បាប់ ដោយមានបិទរូបថត ៤ស.ម គុណ ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ ៤ស.ម គុណ ៦ស.ម ចំនួន ១០ (ដប់) សន្លឹក លិខិតទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជា អំពីគុណសម្បត្តិពិសេស ឬថ្វីដៃពិសេសចំនួន ១(មួយ)ច្បាប់ សេចក្ដីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃពប្រទេសសាមីខ្លួនជនបរទេសចំនួន ២(ពីរ)ច្បាប់ ច្បាប់ថតចម្លង លិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមី៉ខ្លួនដែលនៅមានសុពលភាពចំនួន ២(ពីរ) ច្បាប់ លិខិតថ្កោលទោសមានសុពលភាពត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមី៉ខ្លួនចំនួន ០១ (មួយ) ច្បាប់ លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន ២(ពីរ)ច្បាប់។[115]

ជនបរទេសដែលមានសហព័ទ្ធដែលមានបំណងចង់អោយសហព័ទ្ធទទួលបានសញ្ជាតិដូចខ្លួនដែរ។ សហព័ទ្ធរបស់ជនបរទេសនោះ ត្រូវបំពេញបែបបទតាមករណីដូចដែលបានកំណត់ដូចជា៖ ចំពោះសហព័ទ្ធរបស់ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១ នៃច្បាប់សញ្ជាតិ ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទដូចបានកំណត់ក្នុងមាត្រា ១៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សញ្ជាតិ **លើកលែងតែចំណុចទី៥ (បណ្ណការងារ ឬឯកសារបញ្ជាក់មុខរបរ ឯកសារពាក់ព័ន្ធនឹងការវិនិយោគចំពោះជនបរទេស)** ហើយត្រូវ

[112] យោងតាមចំនុច ២ ប្រការ១៩ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្ដឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

[113] យោងតាមមាត្រា ១៨ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីសញ្ជាតិឆ្នាំ២០១៨

[114] យោងតាមចំនុច ៣ ប្រការ១៩ នៃប្រកាសស្តីពីទម្រង់ និងនីតិវិធីនៃការទទួល និងការពិនិត្យលើសុំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និងនីតិវិធីនៃការប្ដឹងតវ៉ាចំពោះការបដិសេធលើ ការសុំទាមទារសញ្ជាតិខ្មែរ

[115] យោងតាមមាត្រា ១៩ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីសញ្ជាតិឆ្នាំ២០១៨

ភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន ០២ (ពីរ) ច្បាប់ ចំពោះសហព័ទ្ធរបស់ជនបរទេសដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌ត្រូវបំពេញបែបបទដូចបានកំណត់ក្នុងមាត្រា១៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់សញ្ជាតិ **លើកលែងតែចំនុចទី៤ (លិខិតបញ្ជាក់អំពីសាច់ប្រាក់)**ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន ២(ពីរ)ច្បាប់ចំពោះសហព័ទ្ធរបស់ជនបរទេសដែលមានគុណសម្បត្តិពិសេស ឬថ្វីដៃពិសេសត្រូវបំពេញបែបបទ ដូចដែលបានកំណត់ក្នុងមាត្រា ១៩ នៃអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់សញ្ជាតិ **លើកលែងតែចំនុច ទី៤ (លិខិតទទួលស្គាល់ពីគុណសម្បត្តិ ឬស្នាដៃពិសេស)** ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន ២(ពីរ)ច្បាប់។[116]

រីឯជនបរទេសដែលមានកូនជាអនីតិជនដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មអាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ។ ក្នុងករណីនេះ ឪពុកម្តាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូនដូចជា៖ ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ)ច្បាប់ ជីវប្រវត្តិសង្ខេបរបស់កូនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ ៤ស.ម គុណ ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ ៤ស.ម គុណ៦ស.ម ១០(ដប់) សន្លឹក សេចក្តីចម្លងសបុត្រកំណើតរបស់កូនចំនួន ២(ពីរ)សន្លឹក ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់កូនដែលនៅមានសុពលភាពចំនួន ២(ពីរ) ច្បាប់ លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់កូនចំនួន ០១ (មួយ) ច្បាប់ ប្រសិនបើកូននោះមានអាយុ ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំលិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់ ប្រសិនបើកូននោះមានអាយុ ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ហើយបានមករស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងលិខិតបញ្ជាក់សុខភាពរបស់កូនចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន ២(ពីរ) ច្បាប់។[117]

បន្ទាប់ពីបានបំពេញសំណើនេះចប់សព្វគ្រប់អស់ហើយ មន្ត្រីដែលមានសមត្ថកិច្ចនឹងធ្វើការកោះអញ្ជើញអ្នក ដែលដាក់ពាក្យសុំសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មមកប្រឡង ដែលរៀបចំឡើងដោយគណៈកម្មការវាយតម្លៃរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ ការប្រឡងត្រូវធ្វើឡើងដោយការសម្ភាសន៍ ដើម្បីត្រួតពិនិត្យលក្ខណសម្បត្តិ កាយសម្បទា កិរិយាមារយាទ បញ្ញាស្មារតី ការនិយាយស្តាប់ភាសាខ្មែរ ការចេះអាន សរសេរអក្សរខ្មែរ និងការយល់ដឹងនូវប្រវត្តិសាស្ត្រខ្មែរខ្លះៗ និងការពិនិត្យលើភស្តុតាងដែលបានបញ្ជាក់ថា សាមីខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់ល្អរបស់ខ្មែរ។ ក្នុងករណីចាំបាច់ គណៈកម្មការវាយតម្លៃ អាចចាត់មន្ត្រីរបស់ខ្លួន

[116] យោងតាមមាត្រា ២០ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[117] យោងតាមមាត្រា ២១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

អោយចុះអង្កេតពីស្ថានភាពនៃជីវភាពរស់នៅ ឬការប្រកបអាជីវកម្ម ឬទីតាំងវិនិយោគជាក់ស្តែង ឬសមិទ្ធិផលនានារបស់អ្នកដាក់ពាក្យ។ ករណីដែលពិនិត្យឃើញថា អ្នកដាក់ពាក្យសុំមិនឆ្លើយតបតាមលក្ខខណ្ឌខាងលើនៃប្រការនេះ គណៈកម្មការប្រឡងត្រូវរាយការណ៍សុំការសម្រេចពន្យាពេលយ៉ាងតិច ៣ខែ ពីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ហើយការប្រឡងនឹងត្រូវធ្វើឡើងវិញរហូតដល់សាមីខ្លួនអ្នកដាក់ពាក្យសុំបំពេញបានតាមលក្ខខណ្ឌ។ គណៈកម្មការត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីមូលហេតុនៃការពន្យាពេល ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ និងទទួលបានការឯកភាពពីអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

ចំពោះសំណើរសុំចូលសញ្ជាតិខ្មែរណាមួយដែលពិនិត្យឃើញថា មានភាពមិនប្រក្រតី អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច។ បន្ទាប់ពីការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវជូនដំណឹងដល់សាមីអ្នកដាក់ពាក្យសុំក្នុងរយៈពេល ៥ថ្ងៃនៃ ថ្ងៃធ្វើការ។

**កថាខណ្ឌទី ២ អានុភាពនៃការទទួលបានសញ្ជាតិខ្មែរ**

ចំពោះការកំណត់សមត្ថភាពរបស់រូបវន្តបុគ្គលនៃការទទួលបានសិទ្ធិ និងករណីយកិច្ចរបស់ពលរដ្ឋខ្មែរ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មានដូចខាងក្រោម៖

១ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាព ឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។[118]

២ ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន។ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ។[119]

៣ ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។ ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ។ ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់។[120]

[118] យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[119] យោងតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[120] យោងតាមមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

៤ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុ ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត។[121]

៥ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។[122]

៦ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់។[123]

៧ សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។[124]

៨ ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំ ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់

[121] យោងតាមមាត្រា ៣៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[122] យោងតាមមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[123] យោងតាមមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[124] យោងតាមមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។[125]

៩ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។[126]

១០ សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព។ ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។ ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិតតាមសារទូតលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា។ ការឆែកឆេរលំនៅឋានសម្ភារៈវត្ថុ និងលើរូបវន្តបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់។[127]

១១ ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារពត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។[128]

១២ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមកការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម។[129]

១៣ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។[130]

១៤ ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ឋិតនៅក្រោមការគាំពារនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ

[125] យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[126] យោងតាមមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[127] យោងតាមមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[128] យោងតាមមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[129] យោងតាមមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[130] យោងតាមមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។[131]

១៥ ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវលុបបំបាត់ចោល។ ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ។[132]

១៦ អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់នារី ត្រូវហាមឃាត់។ ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។[133]

១៧ មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ។[134]

១៨ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។[135]

១៩ រដ្ឋគាំពារប្រឆាំងនិងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខមាលភាពរបស់កុមារ។[136]

២០ ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។ ប្រជាពលរដ្ឋខ្មែរគ្រប់ រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ។ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់។[137]

[131] យោងតាមមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[132] យោងតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[133] យោងតាមមាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[134] យោងតាមមាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[135] យោងតាមមាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[136] យោងតាមមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[137] យោងតាមមាត្រា ៥០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២១ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិ ស្របច្បាប់របស់ឯកជន។[138]

ចំពោះការកំណត់សមត្ថភាពរបស់រូបវន្តបុគ្គលនៃការទទួលបានសិទ្ធិ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ យោងតាមមាត្រា ៦ ដល់មាត្រា១៦[139] បានកំណត់ដូចខាងក្រោមៈ

- រូបវន្តបុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។

- ចំពោះការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេសវិញ ជនបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។

- នៅពេលចាប់ផ្តើម និងបញ្ចប់សមត្ថភាពទទួលសិទ្ធិៈ រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលសិទ្ធិនេះ នៅពេលទទួលមរណៈភាព។

- ចំពោះសិទ្ធិបុគ្គល គឺជាការពាក់ព័ន្ធនឹងជីវិតរូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬសិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល។

- សិទ្ធិទាមទារឱ្យបញ្ឈប់ៈ ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬមានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ និងអាចបន្ត ឬនឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន។

- សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ ៖ បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែមានជាបន្តបន្ទាប់ ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបាន ទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះអាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាព រំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន។

- សិទ្ធិទាមទារសំណងការខូចខាតៈ បញ្ញត្តិនៃមាត្រា១១ និង១២ នៃក្រមនេះ មិនរារាំងការទាមទារសំណងការខូចខាតដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណ បុគ្គលនោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ។

- ការខ្វះសមត្ថភាពខាងឆន្ទៈ៖ សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនអាចលុបចោលបាន។

[138] យោងតាមមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[139] យោងតាមមាត្រា ៦ ដល់១៦ នៃរដ្ឋប្បវេណីឆ្នាំ២០០៧

- ពាក្យ សកម្មភាព ដែលត្រូវបានប្រើនៅក្នុងផ្នែកទី៣ (សមត្ថភាពខាងធន្ទ:) ផ្នែកទី៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និងផ្នែកទី៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី១ នេះ សំដៅទៅលើកិច្ចសន្យា និងសកម្មភាពឯកតោភាគី។

- ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។

## ផ្នែកទី ២ ការបាត់បង់សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល និងទោសបញ្ញត្តិ

### កថាខណ្ឌទី ១ ការបាត់បង់សញ្ជាតិខ្មែររបស់រូបវន្តបុគ្គល

ចំពោះការបោះបង់សញ្ជាតិខ្មែរ ត្រូវគោរពទៅតាមគោលការណ៍ច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ ២០១៨ ដូចខាងក្រោម៖

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ឆ្នាំ យ៉ាងតិច អាចសុំលះបង់ សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ និងត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន។[140] ចំពោះបែបបទ នីតិវិធីនៃការសុំលះបង់សញ្ជាតិ និងការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ និងសម្រេចដោយព្រះរាជាក្រឹត្យ។[141]

ចំពោះបែបបទ និងនីតិវិធីវិញ ត្រូវគោរពទៅតាមអនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨ មានដូចខាងក្រោម៖

ជនណាមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបានក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត និងដោយគ្មានការបង្ខិតបង្ខំ។ ពលរដ្ឋខ្មែរដែលមានបំណងសុំលះបង់សញ្ជាតិខ្មែរ ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។ ពលរដ្ឋខ្មែរដែលសុំលះបង់សញ្ជាតិខ្មែរត្រូវដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ និងត្រូវបំពេញបែបបទដូចខាងក្រោម៖

ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន ០២ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ០២ច្បាប់ ដោយមានបិទរូបថតទំហំ ៤ស.ម គុណ ៦ស.ម រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ ៤ស.ម គុណ ៦ស.ម ចំនួន ១០សន្លឹក លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិចំនួន ០១ច្បាប់ ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅចំនួន ០២ច្បាប់ សេចក្តីចម្លងសំបុត្រកំណើត ឬច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាចំនួន ០២ច្បាប់។ ចំពោះពលរដ្ឋខ្មែររស់នៅបរទេសស្របច្បាប់ត្រូវមានលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួន នៃប្រទេស

---

[140] មាត្រា ២៨ នៃច្បាប់ស្តីពីសញ្ជាតិថ្មី ២០១៨

[141] មាត្រា ២៩ នៃច្បាប់ស្តីពីសញ្ជាតិថ្មី ២០១៨

នោះចំនួន ០១ច្បាប់។ លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀតរបស់សាមីខ្លួន ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែល សាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិ ត្រូវមានបញ្ជាក់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនោះ និងត្រូវបកប្រែជាភាសាខ្មែរ ឬអង់គ្លេស។[142]ឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែល ផ្តល់សញ្ជាតិ ត្រូវមានបញ្ជាក់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនោះ និងត្រូវបកប្រែជាភាសាខ្មែរ ឬអង់គ្លេស។[143]

រីឯពលរដ្ឋខ្មែរដែលមានកូនជាអនីតិជន មានបំណងស្នើសុំលះបង់សញ្ជាតិខ្មែរ អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារបាន។ ក្នុងករណីនេះ ឪពុក ឬម្តាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូនដូចខាងក្រោម៖

ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន ០២ច្បាប់ ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ០២ច្បាប់ ដោយមានបិទរូបថតទំហំ ៤ស.ម គុណ ៦ស.ម។ រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ ៤ស.ម គុណ ៦ស.ម ចំនួន ១០សន្លឹក លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិចំនួន ០១ច្បាប់។ ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅចំនួន ០២ច្បាប់។ សេចក្តីចម្លងសំបុត្រកំណើតរបស់កូនចំនួន ០២ច្បាប់ ច្បាប់ចម្លងលិខិតឆ្លងដែនរបស់កូនដែលនៅមានសុពលភាពចំនួន ០២ច្បាប់។

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ពលរដ្ឋខ្មែរកំពុង រស់នៅត្រូវមានការផ្តល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។ ទម្រង់និង នីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃសុំការលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ការដាក់ពាក្យសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរត្រូវបង់កម្រៃសេវា។ កម្រៃសេវានៃការដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរដល់ពលរដ្ឋខ្មែរត្រូវសម្រេចដោយព្រះរាជាក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទសុំលះបង់សញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨ និងបែបបទដែល

[142] ចំនុច១ ប្រការ២២ នៃប្រកាសស្តីពី ទម្រង់និង នីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និង នីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើការសុំទាមទារសញ្ជាតិខ្មែរ

[143] ចំនុច២ ប្រការ២២ នៃប្រកាសស្តីពី ទម្រង់និង នីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និង នីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើការសុំទាមទារសញ្ជាតិខ្មែរ

មានចែងក្នុងមាត្រា៣២ និង៣៣ នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍ អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ នៃថ្ងៃធ្វើការ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ និងបន្តនីតិវិធីលើការសុំលះបង់សញ្ជាតិខ្មែរ ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

**កថាខណ្ឌទី ២ ទោសបញ្ញត្តិ**

ចំពោះការកំណត់ទៅលើទោសបញ្ញត្តិវិញ ក៏បានគោរពទៅតាមច្បាប់ ស្ដីពី សញ្ជាតិ ឆ្នាំ២០១៨ ដូចខាងក្រោម៖

ជនបរទេសណាដែលកាន់កាប់ និងប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដន្ទាទោសដាក់ពន្ធធានាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ មន្ត្រី ភ្នាក់ងាររាជការ ឬជនណាធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ឱ្យជនណាម្នាក់ដែលមិនមានសញ្ជាតិខ្មែរត្រូវផ្ដន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ ខាងលើនៃមាត្រានេះ។[144]

ជនណាដែលក្លែងបន្លំ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។ ត្រូវចាត់ទុកជាការក្លែងបន្លំផងដែរនូវអំពើធ្វើការកោសលុប សរសេរបន្ថែម ឬធ្វើឱ្យខូចខាតការពិតនូវព័ត៌មាននៅក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា។[145]

ជនណាដែលប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាក្លែងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤,០០០,០០០រ (បួនលានរៀល) ទៅ ១០,០០០,០០០រ (ដប់លានរៀល)។[146]

អ្នកផ្ដើមគំនិត និងអ្នកសមគំនិតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣០ ៣១ និង៣២នៃច្បាប់នេះស្របតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ។[147] ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០ ៣១ និង៣២ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៥ (ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។[148]

---

[144] មាត្រា ៣០ នៃច្បាប់ស្ដីពីសញ្ជាតិថ្មី ២០១៨
[145] មាត្រា ៣១ នៃច្បាប់ស្ដីពីសញ្ជាតិថ្មី ២០១៨
[146] មាត្រា ៣២ នៃច្បាប់ស្ដីពីសញ្ជាតិថ្មី ២០១៨
[147] មាត្រា ៣៣ នៃច្បាប់ស្ដីពីសញ្ជាតិថ្មី ២០១៨
[148] មាត្រា ២៤ នៃច្បាប់ស្ដីពីសញ្ជាតិថ្មី ២០១៨

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សា និងស្រាវជ្រាវទៅលើទម្រង់នៃការចូលសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល ដោយបានយល់ច្បាស់ និងឱ្យទទួលបានចំណេះដឹងកាន់តែច្បាស់ទៀត អំពីនីតិវិធីនៃការចូលសញ្ជាតិខ្មែរ។ ជាពិសេសច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១០៩៦/៣០ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងជំនួសដោយច្បាប់នេះ ដោយយោងតាមមាត្រា ៣៧ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨។ លើសពីនេះទៅទៀត អនុក្រឹត្យលេខ១១២ អនក្រ.បក ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ ដែលបង្កើតឡើងក្នុងគោលបំណងធានាការអនុវត្តបែបបទ និងនីតិវិធីក្នុងការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ បែបបទ និងនីតិវិធីក្នុងការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសដោយសញ្ជាតូបនីយកម្ម និងបែបបទ និងនីតិវិធីក្នុងការសុំលះបង់សញ្ជាតិខ្មែររបស់ពលរដ្ឋខ្មែរដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំ។ ច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨នេះ ពិតជាមានអត្ថប្រយោជន៍ និងផ្តល់ភាពងាយស្រួលណាស់ សម្រាប់ជនបរទេសដែលជាមានបំណងចង់ចូលសញ្ជាតិខ្មែររបស់ជនបរទេសដែលមកធ្វើវិនិយោគជាលក្ខណៈចង្កោមគ្រួសារ ឬតែរូបវន្តបុគ្គលតែម្នាក់តាមរយៈការដាក់ទុនវិនិយោគ និងដោយការរៀបអាពាហ៍វាងជនបរទេសនិងពលរដ្ឋខ្មែរ ដោយធ្វើឱ្យមានលក្ខណៈកាន់តែប្រសើរឡើងចំពោះបរិបទនៃសង្គមខ្មែរនានាពេលបច្ចុប្បន្ន។ ជាពិសេស ធ្វើយ៉ាងណាទាក់ទាញនូវវិនិយោគិនឱ្យមកធ្វើវិនិយោគនៅក្នុងប្រទេសកម្ពុជាមានចំនួនច្រើនឡើង ដើម្បីធ្វើឱ្យថវិកាជាតិមានការកើនឡើងគួរឱ្យកត់សម្គាល់។ រាល់ការទទួលបានសញ្ជាតិខ្មែរ ឬការទាមទារសញ្ជាតិខ្មែររបស់រូបវន្តបុគ្គល គឺត្រូវតែគោរពទៅតាមទម្រង់បែបបទ និងនីតិវិធីរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ព្រមទាំងទទួលដោយការឧបត្ថម្ភថវិកាជូនរដ្ឋ ឬការប្រគល់ថវិកាជូនរដ្ឋដែលអន្តរក្រសួងបានកំណត់។ ដូចនេះ កាន់តែធ្វើឱ្យថវិកាជាតិ និងព្រះរាជាណាចក្រកម្ពុជាកាន់តែរីកចំរើន និងកើនឡើងជាបន្តបន្ទាប់។ លើសពីនេះទៅទៀត ក៏ធ្វើឱ្យព្រះរាជាណាចក្រកម្ពុជារីកចំរើននូវធនធានមនុស្សដែលមានសមត្ថភាព និងចំណេះដឹងក្នុងការដើរទៅលើឆាកអន្តរជាតិដោយពុំមានការរុញរា។ ជាពិសេស ធ្វើឱ្យប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសសម្បូរទៅដោយការងារគ្រប់បែបយ៉ាង ដែលវិនិយោគនីមួយៗត្រូវការកម្លាំងប្រាជ្ញា និងស្មារតីក្នុងការងារដោយមិនចាញ់ពលរដ្ឋដទៃឡើយ។

សរុបមក ការបង្កើតច្បាប់ស្តីពីសញ្ជាតិខ្មែរឆ្នាំ២០១៨ គឺបង្កើតឡើងដោយមើលទៅលើបរិបទនៃសង្គមខ្មែរនាពេលបច្ចុប្បន្ន ដោយការវិនិយោគក៏មានចំនួនច្រើន សមត្ថភាពធនធានមនុស្សក៏កាន់តែខ្លាំងប្រកបដោយសមត្ថភាព និងចំណេះដឹង និងធ្វើឱ្យថវិកាជាតិកាន់តែកើនឡើងជាលំដាប់ដោយសារតែការចូលមករបស់វិនិយោគិន។

# អនុសាសន៍

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ ទៅលើការចូលសញ្ជាតិខ្មែរ ទៅតាមច្បាប់ ស្តីពី សញ្ជាតិ ឆ្នាំ២០១៨នេះ យើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវបានដឹង បានយល់កាន់តែច្បាស់អំពីបរិបទនៃការទទួលបានសញ្ជាតិខ្មែរ តាមរយៈច្បាប់ ស្តីពី សញ្ជាតិនេះកាន់តែច្បាស់ និងបានឃើញអំពីគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនដែលមានក្នុងច្បាប់ ស្តីពី សញ្ជាតិនេះផងដែរ។

ច្បាប់ថ្មីនេះបានផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋខ្មែរដែលមាន បំណងចង់ធ្វើការសុំកូនជាជនជាតិបរទេសមកធ្វើជាកូនស្មុំរបស់ខ្លួន ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជាពិសេសសំរាប់វិនិយោគិនបរទេសដែលមានបំណងចង់ធ្វើសុំចូលសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្មផងដែរ។

ផ្ទុយទៅវិញ ច្បាប់ ស្តីពី សញ្ជាតិថ្មីនេះក៏មានក៏មានគុណវិបត្តិមួយចំនួនដែលជាផលអវិជ្ជមានដល់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជាផងដែរ។ ពោលដូចដែលមានករណីបាក់អាគារក្នុងខេត្តព្រះសីហនុ បង្កើតឱ្យមានហានិភ័យខ្ពស់ទៅដល់ប្រជាពលរដ្ឋកម្ពុជា និងភាពអណាធិបតេយ្យដែលតែងតែកើតមានឡើងជារឿយៗនៅខេត្តព្រះសីហនុ។

ដូចនេះក្នុងនាមខ្ញុំជាប្រជាពលរដ្ឋខ្មែរ ជាអ្នកសិក្សាស្រាវជ្រាវលើប្រធានបទនេះយើងខ្ញុំរំពឹងទុកថា រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មី នឹងយកចិត្តទុកដាក់ និងពង្រឹងភាពម៉ឹងម៉ាត់ទៅលើការអនុវត្ត និងការត្រួតពិនិត្យទៅលើនីតិវិធីនៃការស្នើសុំចូលសញ្ជាតិខ្មែរទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីសញ្ជាតិខ្មែរអោយកាន់តែមានប្រសិទ្ធិភាពជាងនេះទៅទៀត។ លើសពីនេះទៅទៀតយើងខ្ញុំក៏សូមសំណូមពរដល់រាជរដ្ឋាភិបាលចំពោះការអនុវត្តច្បាប់ឱ្យកាន់តែមុតមាំ និងមានតម្លាភាព។ ជាពិសេសចំពោះការបង្កើតលិខិតបទដ្ឋានគតិយុត្តក្នុងការចូលសញ្ជាតិខ្មែរតាមរយៈសុំកូនពីប្រទេសដទៃ មកចិញ្ចឹមបីបាច់ថែរក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមាននីតិវិធី និងបែបបទ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដើម្បីបន្ថែមឱ្យកាន់តែមានលក្ខខណ្ឌសម្គាល់កាន់តែច្បាស់នៅក្នុងបរិបទច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ឯកសារយោង

### ច្បាប់ជាតិ

- រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
- ច្បាប់សញ្ជាតិ ឆ្នាំ ២០១៨
- ច្បាប់ ស្តីពី ការវិនិយោគនៃកម្ពុជា ឆ្នាំ ១៩៩៤
- ច្បាប់ ស្តីពី ការសម្ភុំកូនអន្តរប្រទេស ឆ្នាំ ២០០៩
- ច្បាប់ ស្តីពី អន្តោប្រវេសន៍ ឆ្នាំ ១៩៩៤
- ច្បាប់ ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនិងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៦

### ច្បាប់អន្តរជាតិ

- ធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ ១៩៤៥
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨
- ច្បាប់ស្តីពីការសុំកូនអន្តរប្រទេសរបស់ប្រទេសភីលីពីន The Inter-Country Adoption Act of 1995 " AN ACT ESTABLISHING THE RULES TO GOVERN INTER-COUNTRY ADOPTION OF FILIPINO CHILDREN AND OTHER PURPOSES ឆ្នាំ ១៩៩៥

### អនុក្រឹត្យ

- អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨
- អនុក្រឹត្យ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ ២០០៨
- អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន ឆ្នាំ ២០០០
- អនុក្រឹត្យស្តីពី បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតិអោយជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៦
- អនុក្រឹត្យលេខ ១០៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនប្រទេស ឆ្នាំ ២០០៨
- អនុក្រឹត្យស្តីពីការសុំកូនកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស ឆ្នាំ ២០០១

## ប្រកាស

- ប្រកាសស្ដីពី ទម្រង់និង នីតិវិធីនៃការទទួល និងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការសុំលះបង់សញ្ជាតិខ្មែរ និងទម្រង់និង នីតិវិធីនៃការប្ដឹងតវ៉ាចំពោះការបដិសេដលើការសុំទាមទារសញ្ជាតិខ្មែរ ឆ្នាំ ២០១៨

## កម្រងឯកសារផ្សេងៗ

- កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ឆ្នាំ ២០០៥
- វចនានុក្រមសម្ដេច ជួនណាត

## គេហទំព័រផ្សេងៗ

- https://www.countries-ofthe-world.com ( 7 Continental )
- http://www.un.org ( Member States )
- https://thmeythmey.com
- http://ouk-i.blogspot.com/2017/08/blog-post.html

## ឯកសារដែលនិរាករណ៍

- ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ ១៨៦៧
- ច្បាប់សញ្ជាតិ ឆ្នាំ ១៩៩៦
- ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ ១៩៨៦
- អនុក្រឹត្យស្ដីពី បែបបទ និងនីតិវិធីនៃការសុំសញ្ជាតិតូបនីយកម្ម ឆ្នាំ ២០១៣
- អនុក្រឹត្យស្ដីពី បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ឆ្នាំ ២០១៣
- អនុក្រឹត្យស្ដីពីនីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ ឆ្នាំ ២០១៣